# គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីនៅកម្ពុជា

---

## របាយការណ៍ការពិនិត្យមើលឡើងវិញ

**ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៩**

របាយការណ៍នេះបង្ហាញអំពីលទ្ធផលដែលរកឃើញ និង អនុសាសន៍នានា ពីការពិនិត្យមើលឡើងវិញលើគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។ របាយការណ៍នេះបានដាក់ជូនទៅរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩។

# សារៈសំខាន់ៗ

១. គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) គឺជាគម្រោងរដ្ឋបាលនិងរៀបចំដីធ្លីដ៏ពេញលេញមួយ ដែលរួមមានការវិនិយោគនានា ដើម្បីអភិវឌ្ឍគោលនយោបាយ និងលិខិតូបករណ៍គតិយុត្តិនិងគ្រប់គ្រងពាក់ព័ន្ធ ការកសាងសមត្ថភាព យន្តការដោះស្រាយវិវាទដីធ្លី និងការប័ណ្ណកម្មសិទ្ធិដី និងការចុះបញ្ជីដីធ្លី។ សកម្មភាព LMAP គ្រោងអនុវត្តនៅក្នុង "ខេត្តអនុវត្តគម្រោង" ចំនួន ១១[១] ។ គោលដៅអភិវឌ្ឍន៍នៃគម្រោង គឺដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកម្មវិធីគោលនយោបាយដីធ្លីរបស់ខ្លួនដូចដែលត្រូវបានកំណត់នៅកាលពីខែ ឧសភា ឆ្នាំ ២០០១ និង ជាក់ស្តែងជាងនេះទៀត គឺដើម្បីកែលម្អសុវត្ថិភាពកាន់កាប់ដី និង ជម្រុញការអភិវឌ្ឍទីផ្សារដីប្រកបដោយប្រសិទ្ធភាព ។

២. គម្រោង LMAP បានសម្រេចអត្ថប្រយោជន៍ដោយឥតសង្ស័យបាន រួមមានការចុះបញ្ជីនិងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជិតមួយលានក្បាលដី។ ជោគជ័យផ្សេងទៀត រួមមានការពង្រឹងស្ថាប័ន ការកែលម្អគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តិដីធ្លី និង ការពង្រឹងគណៈកម្មការសុរិយោដី ។

៣. ប៉ុន្តែ គេឃើញមានភាពដាច់ពីគ្នារវាងសមិទ្ធផលផ្នែកស្ថាប័ន នីតិកម្ម និងគោលនយោបាយ និង អសុវត្ថិភាពនៃការកាន់កាប់ដីសម្រាប់ប្រជាជនក្រីក្រ ជាពិសេស នៅតំបន់ទីក្រុង និង សម្រាប់ជនជាតិដើមភាគតិច ។ ភាពដាច់ពីគ្នានេះអាចត្រូវបានផ្សារភ្ជាប់មួយផ្នែកទៅនឹងការរៀបចំសមាសភាគមួយចំនួននៃគម្រោងមួយផ្នែកទៅនឹងរបៀបដែលគម្រោងត្រូវបានអនុវត្ត ក៏ដូចជា ការយឺតយ៉ាវ ឬ ការមិនអនុវត្តសកម្មភាពខ្លះ និង មួយផ្នែកទៅនឹងការវិវត្តដ៏លឿននៅក្នុងទីផ្សារដី ដែលការវិវត្តនេះខ្លះមានលក្ខណៈហួសពីសមត្ថកិច្ចផ្ទាល់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលទទួលបន្ទុកលើការអនុវត្តគម្រោង LMAP ។ ជាលទ្ធផល ជោគជ័យគួរឱ្យកត់សម្គាល់របស់គម្រោង LMAP ក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅតាមតំបន់ជនបទ មិនត្រូវបានសម្រេចដូចគ្នានៅតំបន់ទីក្រុងនៃខេត្តអនុវត្តគម្រោងទេ ដែលបានគេដឹងថាមានវិវាទដីធ្លីច្រើនជាង ។

៤. នៅក្នុងពេលរៀបចំ មានសេចក្តីសម្រេចមួយស្របគ្នាជាមួយនឹងច្បាប់កម្ពុជាដែលកំណត់ថា "គម្រោងនឹងមិនផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅក្នុងតំបន់ទាំងឡាយដែលទំនងជាមានវិវាទទេ រហូតដល់ពេលដែលមានកិច្ចព្រមព្រៀងគ្នាអំពីស្ថានភាពដី ។" ការបំភ្លឺអំពីស្ថានភាពដីមុខជាតម្រូវឱ្យមានការរៀបចំនិងការអនុវត្តនីតិវិធីច្បាស់លាស់សម្រាប់ការធ្វើចំណាត់ថ្នាក់ដីរបស់រដ្ឋ ដែលត្រូវបានគ្រោងធ្វើក្រោមសមាសភាគទី ៥ ប៉ុន្តែត្រូវបានអនុវត្តតែមួយផ្នែកប៉ុណ្ណោះ ដែលបណ្តាលឱ្យមានអវត្តមាននៃការគូសផែនទីដីរដ្ឋជាផ្លូវការ ។ ហេតុដូច្នេះ ផ្ទៃដីមួយចំនួនមិនត្រូវបានដាក់បញ្ចូលក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ

[១] ខេត្តគម្រោងចំនួនបីទៀតត្រូវបានបន្ថែមក្រោមជំនួយឥតសំណងរបស់អង្គការ CIDA ។ ចំនួនខេត្តសរុបដែលស្ថិតក្រោមគម្រោងបច្ចុប្បន្ននេះគឺ ១៤ ។

*ដោយគ្មានការផ្តល់លក្ខណៈវិនិច្ឆ័យឬការពន្យល់ច្បាស់លាស់ជូនសហគមន៍មូលដ្ឋានឡើយ[២] ។ ចំណុចនេះបង្កើតភាពដាច់ពីគ្នាមួយជាមួយគោលដៅនៃគម្រោង LMAP ក្នុងការលើកកម្ពស់សុវត្ថិភាពដី ដូច្នេះ គប្បីត្រូវពិនិត្យមើលនិងកែតម្រូវឡើងវិញ ។*

៥. *ការបណ្តេញចេញនានានៅពេលថ្មីៗនេះ គូសបង្ហាញនូវភាពចាំបាច់ឱ្យរាជរដ្ឋាភិបាលពន្លឿនការអនុម័តចំណុចទាំងឡាយនៃកំណែទម្រង់វិស័យដីធ្លីដែលការពារសិទ្ធិដីធ្លីរបស់អ្នកប្រើប្រាស់ដី ភោគៈ និង ម្ចាស់កម្មសិទ្ធិទាំងអស់ ។ ដោយសារចំណុចខ្សោយនានាដែលបានគូសបង្ហាញខាងលើទាំងនៅក្នុងការរៀបចំនិងការអនុវត្តគម្រោង ក៏ដូចជាការមិនអនុវត្តកម្មវិធីតាំងលំនៅឋានក្រៅប្រព័ន្ធគ្រោងទុកដែលត្រូវអនុវត្តទន្ទឹមគ្នានឹងគម្រោង LMAP គម្រោង LMAP មិនបានបង្ហាញថាគឺជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពមួយសម្រាប់ជួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយការតាំងលំនៅឋានក្រៅប្រព័ន្ធ ។ ចំពោះមុខគោលដៅនៃការលើកកម្ពស់សុវត្ថិភាពដីនៃគម្រោង LMAP វាគឺជាប្រការសំខាន់ដែលធនាគារពិភពលោកនិងរាជរដ្ឋាភិបាលចាំបាច់ត្រូវឯកភាពគ្នាអំពីវិធីដោះស្រាយចំណុចខ្វះខាតនេះ នាពេលខាងមុខ ។*

៦. *នាពេលខាងមុខ ធនាគារពិភពលោកនឹងចាំបាច់ត្រូវឯកភាពជាមួយរាជរដ្ឋាភិបាល និង ជួយគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការកែតម្រូវ ដោយពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាដែលរួមមានប្រជាជនរងផលប៉ះពាល់ ដើម្បីដោះស្រាយចំណុចខ្វះខាតនានានៅក្នុងការរៀបចំនិងការអនុវត្តគម្រោង LMAP ។ម្យ៉ាងទៀត ធនាគារពិភពលោក និង ដៃគូអភិវឌ្ឍន៍គម្រោង LMAP ផ្សេងទៀត គប្បីពាក់ព័ន្ធរាជរដ្ឋាភិបាលនៅក្នុងការពិភាក្សាគោលនយោបាយវិស័យដីធ្លីដ៏ទូលាយមួយ ដើម្បីជម្រុញឱ្យរាជរដ្ឋាភិបាលអនុវត្តគោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ចនៃគម្រោង LMAP ដើម្បីសម្របនីតិវិធីទាំងឡាយដែលត្រូវបានប្រើនៅក្នុងសកម្មភាពនានាដែលទទួលហិរញ្ញប្បទានពីគម្រោងLMAP ទៅនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិនិងសកម្មភាពចុះបញ្ជីដីធ្លីនៅតាមខេត្ត/រាជធានី ។*

[២] ដោយសារការបណ្តេញចេញបានកើតឡើងនៅលើផ្ទៃដីមានវិវាទ ដែលមិនត្រូវបានដាក់បញ្ចូលក្នុងការអនុវត្តគម្រោង LMAP ការតាំងលំនៅឋានថ្មីនិងក្របខ័ណ្ឌគោលនយោបាយការពារមិនត្រូវបានសាកល្បងទេ ។

# របាយការណ៍របស់បេសកកម្មសិក្សាវាយតម្លៃគម្រោង LMAP

## I. សារៈតារនៃបេសកកម្មសិក្សាវាយតម្លៃ

១. សមាសភាពនៃបេសកកម្មសិក្សាវាយតម្លៃ (ERM) រួមមានលោក ម៉ាហាម៉ាដ បេខេឈី (Mohammed A. Bekhechi) (អ្នកច្បាប់ជាន់ខ្ពស់ (Lead Counsel) ធនាគារពិភពលោក) និង លោក ឡារស៏ លុនដ៏ (Lars Lund) (ទីប្រឹក្សាផ្នែកកិច្ចការពារសង្គម)។ បេសកកម្មសិក្សាវាយតម្លៃបានជួបជាមួយភាគីពាក់ព័ន្ធនានា[៣] និងបានធ្វើការសិក្សាវាយតម្លៃ របស់ខ្លួនពីថ្ងៃទី ៣០ ខែ មីនា ដល់ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៩ ដោយមានគោលដៅពីរដូចខាងក្រោម:

ក. ដើម្បីវាយតម្លៃកម្រិតដែលគម្រោង LMAP កំពុងត្រូវបានអនុវត្ត អនុលោមតាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ (DCA) នៃគម្រោង និង ច្បាប់ភូមិបាលកម្ពុជា និង

ខ. ទាក់ទងនឹងករណីបណ្តេញចេញនាពេលថ្មីៗនេះ ដើម្បីផ្តល់ជូនថ្នាក់គ្រប់គ្រងធនាគារពិភពលោកនូវការវាយតម្លៃដ៏ហ្មត់ចត់មួយអំពីស្ថានភាពជាក់ស្តែង រួមទាំងលទ្ធភាពផ្សារភ្ជាប់គ្នារវាងគម្រោង LMAP និង ការបណ្តេញចេញទាំងនេះ។

២. ជាពិសេស បេសកកម្មសិក្សាវាយតម្លៃត្រូវបានស្នើសុំឱ្យផ្តល់ជូនថ្នាក់គ្រប់គ្រងនូវចម្លើយនានាចំពោះសំណួរខាងក្រោមនេះ:

ក. តើមានភាពដាច់ពីគ្នាណាមួយឬទេរវាងគម្រោង LMAP ដូចដែលត្រូវបានរៀបចំនិងអនុវត្ត ជាពិសេស ទាក់ទិនទៅនឹងការយឺតយ៉ាវ/ការមិនអនុវត្តសកម្មភាពជាក់លាក់ណាមួយ និង/ឬ សមាសភាគនៃគម្រោង?

ខ. តើសេចក្តីសម្រេចចិត្តនៃការរៀបចំក្នុងការមិនដាក់បញ្ចូលតំបន់ទាំងឡាយ ដែលមានវិវាទលើការកាន់កាប់ដីធ្លីមានលក្ខណៈសមស្របឬទេ ចំពោះមុខការឡើងថ្លៃដី ការបង្កើនល្បឿននៃការតាំងលំនៅឋានថ្មី និង ការអនុម័តការបណ្តេញចេញដោយបង្ខំដោយរាជរដ្ឋាភិបាល?

---

[៣] ភាគីពាក់ព័ន្ធទាំងនេះរួមមាន: បុគ្គលិកគម្រោង LMAP នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ បុគ្គលិកគណៈកម្មការសុរិយោដីនៅរាជធានីភ្នំពេញ មន្ត្រីសាលាក្រុងរាជធានីភ្នំពេញ បុគ្គលិកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងការតាំងលំនៅឋានថ្មី អង្គការសង្គមស៊ីវិល និង មេដឹកនាំសហគមន៍ រួមមានសហគមន៍ទាំងឡាយដែលស្ថិតក្រោមការគម្រាមកំហែងនៃការបណ្តេញចេញជៀសមិនផុត ដូចជា ក្រុម ៧៨ តំណាងដៃគូអភិវឌ្ឍន៍ រួមមាន ADB, GTZ, SIDA, CIDA, USAID, FINMAP អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និង ស្ថាប័នអន្តរជាតិនានាដែលមានតំណាងនៅកម្ពុជា និង ដែលពាក់ព័ន្ធនៅក្នុងបញ្ហាសិទ្ធិមនុស្ស និង បុគ្គលនិងក្រុមទាំងឡាយដែលត្រូវបានបណ្តេញចេញពីដីរបស់ខ្លួន ជាពិសេស ចេញពីតំបន់ដីក្រហម និង "ត្រូវបានតាំងលំនៅឋានថ្មី" នៅក្រៅរាជធានីភ្នំពេញ។

គ. តើការតាំងលំនៅឋានថ្មីនៅក្នុងសហគមន៍ទាំងឡាយដែលចូលរួមក្នុងគម្រោង LMAP ត្រូវបានចាត់ចែងតាមវិធីមួយដែលស្របគ្នាជាមួយនឹងក្របខ័ណ្ឌគោលនយោបាយតាំងលំនៅឋានថ្មី ដែលត្រូវបានរៀបចំសម្រាប់គម្រោងនេះ និងគោលនយោបាយការពាររបស់ធនាគារពិភពលោក ដែលត្រូវអនុវត្តចំពោះគម្រោងឬទេ?

ឃ. តើធនាគារពិភពលោកបានខកខានមិនបានស៊ើបមើលលើការចោទប្រកាន់អំពីការបំពាននៅក្នុងការអនុវត្តច្បាប់ភូមិបាល និងមិនបានលើកឡើងអំពីការចោទប្រកាន់ទាំងនេះជូនរាជរដ្ឋាភិបាល ឬទេ?

៣. ផ្នែកខាងក្រោមនៃរបាយការណ៍នេះ ផ្តល់ជូនចម្លើយរបស់បេសកកម្មសិក្សាវាយតម្លៃចំពោះសំណួរទាំងនេះ រួមជាមួយអនុសាសន៍នានាជូនថ្នាក់គ្រប់គ្រងនៃធនាគារពិភពលោក។

## II. គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី

### *ក. សាវតារ*

៤. គម្រោង LMAP (ឥណទានលេខ ៣៦០៥ KH) ត្រូវបានយល់ព្រមនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០២ ជាមួយកាលបរិច្ឆេទបិទគម្រោងនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧។ កាលបរិច្ឆេទនេះត្រូវបានបន្តកាលពីខែ ធ្នូ ឆ្នាំ ២០០៧ ហើយកាលបរិច្ឆេទបិទថ្មីមួយត្រូវបានកំណត់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩។ កាលបរិច្ឆេទនេះក៏ត្រូវបានផ្អាកផងដែរពីខែ មិថុនា ឆ្នាំ ២០០៦ ដល់ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដោយសារបញ្ហាលទ្ធកម្ម ដែលមិនត្រូវបានពិភាក្សាក្នុងរបាយការណ៍នេះទេ។

៥. គោលដៅនៃគម្រោង LMAP ដូចដែលត្រូវបានកំណត់នៅក្នុងឯកសារវាយតម្លៃគម្រោង (PAD) និង កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ គឺដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្ត "កម្មវិធីសកម្មភាព គោលដៅ និងគោលនយោបាយនានារបស់ខ្លួនសំដៅលើកកម្ពស់សុវត្ថិភាពកាន់កាប់ដី និង ជម្រុញការអភិវឌ្ឍទីផ្សារដីប្រកបដោយប្រសិទ្ធភាព[៤]" (កម្មវិធីរបស់រាជរដ្ឋាភិបាល)។ កម្មវិធីនេះរបស់រាជរដ្ឋាភិបាល រួមមាន: (១) "ការអភិវឌ្ឍគោលនយោបាយជាតិគ្រប់គ្រាន់ ក្របខ័ណ្ឌនិងស្ថាប័ននិយ័តកម្មមួយសម្រាប់រដ្ឋបាលដីធ្លី (២) ការចេញនិងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីនៅតំបន់ជនបទ និងទីក្រុងនៅតាមខេត្តអនុវត្តគម្រោង និង (៣) ការបង្កើតប្រព័ន្ធរដ្ឋបាលដីធ្លីប្រកបដោយប្រសិទ្ធភាពនិងតម្លាភាពមួយ[៥]"។ គម្រោង LMAP ត្រូវបានរៀបចំដើម្បីអនុវត្តនៅក្នុង "ខេត្តអនុវត្តគម្រោង"

[៤] សូមមើលកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ (DCA) ផ្នែក (ក)។

[៥] តារាង ២ នៃកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍។

ចំនួន ១១[៦] ដែលត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ថាជា "ខេត្តឬរាជធានីណាមួយនៅក្នុងដែនដីរបស់អ្នកខ្ចី ដែលនៅទីនោះ គម្រោងនឹងត្រូវបានអនុវត្ត"[៧] ។

៦. ដើម្បីសម្រេចបានគោលដៅទាំងនេះ គម្រោង LMAP ផ្តល់ហិរញ្ញប្បទានលើសមាសភាគទាក់ទងគ្នាចំនួនប្រាំ:

សមាសភាគទី ១: អភិវឌ្ឍន៍គោលនយោបាយដីធ្លី និង ក្របខ័ណ្ឌនិយ័តកម្ម

សមាសភាគទី ២: អភិវឌ្ឍន៍ស្ថាប័ន

សមាសភាគទី ៣: កម្មវិធី និងការអភិវឌ្ឍការផ្តល់ប័ណ្ណកម្មសិទ្ធិដី និងប្រព័ន្ធចុះបញ្ជីដីធ្លី

សមាសភាគទី ៤: ពង្រឹងយន្តការដោះស្រាយវិវាទ និង

សមាសភាគទី ៥: ការរៀបចំដែនដី ។

៧. គោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ច (ESG) ត្រូវបានរៀបចំសម្រាប់គម្រោង និងត្រូវបានអនុម័តស្របតាមគោលការណ៍ OP ៤.០១ (ការវាយតម្លៃបរិស្ថាន) គោលការណ៍ OD ៤.៣០ (ការតាំងលំនៅឋានថ្មីមិនស្ម័គ្រចិត្ត) និងគោលការណ៍ OD ៤.២០ (ជនជាតិដើមភាគតិច) របស់ធនាគារពិភពលោក ។ ឯកសារគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គមកិច្ច ចែងថា:

ក. "ក្រោមសមាសភាគការរៀបចំដែនដី [សមាសភាគទី (៥)] គម្រោងនឹងគាំទ្រដល់ការធ្វើចំណាត់ថ្នាក់ដី និងការកំណត់ព្រំដែនដីនៃចំណាត់ថ្នាក់ផ្សេងៗគ្នា ។ ដោយសារការធ្វើសេចក្តីសម្រេចចិត្តទាំងនេះមិនមែនសុទ្ធតែងាយស្រួលនោះទេ គេបានរំពឹងថាកិច្ចដំណើរការនេះ នឹងពាក់ព័ន្ធ*ការចូលរួមដ៏ពេញលេញរបស់ភាគីពាក់ព័ន្ធទាំងអស់ រួមមានស្ថាប័ន រាជរដ្ឋាភិបាលពាក់ព័ន្ធនៅថ្នាក់កណ្តាល ខេត្ត និង មូលដ្ឋាន និង គ្រួសារទាំងឡាយដែលមានទីលំនៅក្នុងតំបន់នោះ" ...។* ម្យ៉ាងទៀត គម្រោងត្រូវបានគ្រោងផ្តល់ការជួយគាំទ្រដល់ការរៀបចំគោលនយោបាយផ្សេងទៀត ដែលរួមមាន [....] គោលនយោបាយនានាដែលគាំទ្រដល់*ការចុះបញ្ជីសិទ្ធិដីធ្លីរបស់សហគមន៍និងជនជាតិដើមភាគតិច និងការបែងចែក និងការអភិវឌ្ឍដីសម្រាប់ប្រជាជនក្រីក្រគ្មានដី* "[៨] [ការគូសបញ្ជាក់ត្រូវបានបន្ថែម]

ខ. "ទោះបីជាគ្មានការបណ្តេញចេញ ការតាំងលំនៅឋានថ្មីមិនស្ម័គ្រចិត្ត ឬ លទ្ធកម្មដីត្រូវបានគ្រោងក្រោមគម្រោងនេះក្តីក៏[ក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងលំនៅឋានថ្មី(RPF)]

---

[៦] តារាង ៦ នៃកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ។

[៧] គេត្រូវកត់សម្គាល់ថាខេត្តបីទៀតត្រូវបានបន្ថែមនៅក្នុងគម្រោង LMAP ក្នុងឆ្នាំ ២០០៧ ក្រោមហិរញ្ញប្បទានរបស់អង្គការ CIDA ។ ពុំមានការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរនេះទេ ។

[៨] ថ្វីបើគម្រោង LMAP មិនមានគ្រោងធ្វើការផ្តល់ប័ណ្ណកម្មសិទ្ធិដោយឡែកនៅតាមតំបន់ទាំងឡាយដែលមានជនជាតិដើមភាគតិចរស់នៅក្តីក៏ក្របខ័ណ្ឌគោលនយោបាយមួយស្តីពីជនជាតិដើមភាគតិចត្រូវបានរៀបចំដែរ ។

ត្រូវបានគ្រោងដែរដើម្បីការពារប្រជាជនដែលអាចរងផលប៉ះពាល់ជាអវិជ្ជមានពីប្រភពចំនួនបី។ ប្រភពទាំងបីនេះ គឺៈ (១) ការបណ្តេញចេញពីដីរបស់រដ្ឋនូវបុគ្គលទាំងឡាយដែលបានកាន់កាប់ដីនោះមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ... ក្រោយការចេញប័ណ្ណកម្មសិទ្ធិដីប្រភេទនេះ ក្នុងនាមរបស់រដ្ឋ (២) ការបណ្តេញចេញពីដីរបស់រដ្ឋដែលត្រូវបានចេញប័ណ្ណកម្មសិទ្ធិក្នុងនាមរបស់រដ្ឋនូវបុគ្គលទាំងឡាយដែលបានកាន់កាប់ដីនោះមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ... ដោយសារភាពចាំបាច់ត្រូវប្រើដីនោះ សម្រាប់ការងារសាងសង់សាធារណៈក្រោមគម្រោង និង (៣) ការពង្រីកដោយរដ្ឋនូវដីចំណីផ្លូវ ដែលប៉ះពាល់ជាអវិជ្ជមានលើសិទ្ធិនៃកម្មសិទ្ធិ។"

## *ខ. ការអនុវត្ត និងសមិទ្ធិផលនានានៃគម្រោង LMAP*

៨. ថ្វីបើគម្រោងរៀបចំដែនដីនិងសុរិយោដីនានាច្រើនបង្ហាញលទ្ធផលតែក្រោយពេលមានកិច្ចប្រឹងប្រែងដ៏យូរនិងជាប់លាប់ក្តី ក៏ គម្រោង LMAP បានសម្រេចអត្ថប្រយោជន៍ដោយឥតសង្ស័យបាននៅក្នុងរយៈពេលដ៏ខ្លី។ គិតមកដល់ខែ មេសា ឆ្នាំ ២០០៩ គម្រោង LMAP បានអនុវត្តសកម្មភាពជាច្រើននៃសកម្មភាពរបស់ខ្លួន និង សម្រេចបានគោលដៅសំខាន់ៗ ដែលរួមមានៈ

ក. ការពង្រឹងស្ថាប័នក្រោមសមាសភាគ (១) និង (២) របស់ខ្លួន ដែលបានផ្តល់ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គភាពគម្រោងរបស់ក្រសួងនេះ គណៈកម្មការសុរិយោដីនៅថ្នាក់ជាតិនិងខេត្ត និងសកលវិទ្យាល័យភូមិន្ទកសិកម្ម នូវបុគ្គលិកបណ្តុះបណ្តាលបានល្អ និងប្រកបដោយសមត្ថភាព បច្ចេកវិទ្យាទំនើប សម្ភារៈ និងកន្លែងធ្វើការ។

ខ. ការលើកកម្ពស់និងការអភិវឌ្ឍបន្ថែមទៀតនូវគោលនយោបាយដីធ្លីនិងក្របខ័ណ្ឌគតិយុត្តិ ដែលរួមមានគោលនយោបាយនិងលិខិតបទដ្ឋានផ្សេងៗ (អនុក្រឹត្យ និងបទបញ្ជានានា) ដែលគ្របដណ្តប់លើបញ្ហាផ្សេងៗជាច្រើនចាប់តាំងពីការបង្កើតផែនការដីធ្លី និងការិយាល័យចុះបញ្ជីដី រហូតដល់ការចុះបញ្ជីដីក្រៅប្រព័ន្ធ សម្បទានដីសង្គមកិច្ច សម្បទានដីសេដ្ឋកិច្ច រហូតដល់ការគ្រប់គ្រងដីរបស់រដ្ឋ និងក្នុងខែ ឧសភា ឆ្នាំ ២០០៩ ដីរបស់ជនជាតិដើមភាគតិច[៥]។

គ. ការពង្រឹងគណៈកម្មការសុរិយោដីដែលទទួលបន្ទុកដោះស្រាយវិវាទដីធ្លី និង

ឃ. ការផ្តល់ប័ណ្ណកម្មសិទ្ធិដីនិងការចុះបញ្ជីដី និងការបង្កើតប្រព័ន្ធទិន្នន័យកណ្តាលមួយដែលមានប្រព័ន្ធចុះបញ្ជីដីធ្លីដោយប្រើកុំព្យូទ័រ។ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីនិងការចុះបញ្ជីដីនៅតំបន់ជនបទគ្មានវិវាទនៅក្រៅដីរបស់ជនជាតិដើមភាគតិច គឺជាជោគជ័យពិតប្រាកដមួយ ជាមួយនឹងប័ណ្ណកម្មសិទ្ធិដីជិតមួយលានត្រូវបានចេញ ដែលហួសពីការប៉ាន់ស្មានវាយតម្លៃទៅទៀត។

---

[៥] អនុក្រឹត្យស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីនិងការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ថ្វីបើអនុក្រឹត្យដែលបានអនុម័តនេះមិនបានដាក់បញ្ចូលអនុសាសន៍និងយោបល់គ្រប់ទាំងអស់ពីភាគីពាក់ព័ន្ធនានាដែលទទួលបាននៅក្នុងដំណាក់កាលតាក់តែងក្តី។

៩. សមិទ្ធិផលទាំងនេះ ត្រូវបានទទួលស្គាល់និងសរសើរដោយភាគីពាក់ព័ន្ធទាំងអស់នៅក្នុងអំឡុងពេលធ្វើការងាររបស់បេសកកម្មសិក្សាវាយតម្លៃ រួមទាំងស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល (CSOs) និង មេដឹកនាំសហគមន៍។ ភាគីពាក់ព័ន្ធទាំងនេះសុទ្ធតែបានសម្តែងឆន្ទៈនិងបំណងប្រាថ្នារបស់ខ្លួនក្នុងការគាំទ្រការវិនិយោគបន្តការងារ ដើម្បីបន្តការងារដែលបានសម្រេចកន្លងមកក្រោមគម្រោង LMAP។ ប៉ុន្តែ អង្គការសង្គមស៊ីវិល និង មេដឹកនាំសហគមន៍ បានសម្តែងសេចក្តីព្រួយបារម្ភអំពីភាពដាច់ពីគ្នាមួយចំនួនរវាងសមិទ្ធិផលផ្នែកស្ថាប័ន គតិយុត្តិ និង គោលនយោបាយរបស់គម្រោង LMAP និង អសុវត្ថិភាពជាបន្តនិងកើនឡើងនៃការកាន់កាប់ដីសម្រាប់ប្រជាជនក្រីក្រនៅតាមតំបន់ទីក្រុង ជាពិសេសនៅរាជធានីភ្នំពេញ និង នៅតាមតំបន់ជនបទមួយចំនួន ដែលនៅទីនោះ មានជនជាតិដើមភាគតិចរស់នៅនិងសប្បាយរីករាយនឹងសិទ្ធិប្រើប្រាស់ដីប្រពៃណី។ ចំណុចទាំងនេះគឺជាបញ្ហាដែលគម្រោង LMAP បានកំណត់នៅក្នុងដំណាក់កាលរៀបចំនិងគ្រោងការងាររបស់ខ្លួន ប៉ុន្តែ នៅមិនទាន់បានដោះស្រាយប្រកបដោយប្រសិទ្ធភាពនៅឡើយ។

## III. សេចក្តីសន្និដ្ឋានរបស់បេសកកម្មសិក្សាវាយតម្លៃ

***សំណួរទី ១: តើមានភាពដាច់ពីគ្នាណាមួយឬទេរវាងគម្រោង LMAP ដូចដែលត្រូវបានរៀបចំនិងអនុវត្ត ជាពិសេស ទាក់ទិនទៅ នឹងការយឺតយ៉ាវ ការមិនអនុវត្តសកម្មភាពជាក់លាក់ណាមួយ និង/ឬ សមាសភាគនៃគម្រោង?***

១០. ឯកសារវាយតម្លៃគម្រោង (ទំព័រ ១២) ចែងថា: "... គម្រោងចំពោះមុខនេះប្រកាន់យកអភិក្រមពេញលេញមួយនៅក្នុងកំណែទម្រង់គោលនយោបាយនិងនិយ័តកម្មគាំទ្រ ការកសាងភាពស្រុះស្រួលគ្នា និង ការអភិវឌ្ឍស្ថាប័ន រួមជាមួយនឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដី។ *ឯកសារនេះកំណត់លំដាប់លំដោយសកម្មភាពយ៉ាងប្រយ័ត្នប្រយែង ដើម្បីកុំឱ្យការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធត្រូវធ្វើឡើងនៅលើដីដែលមានស្ថានភាពមិនច្បាស់លាស់ រហូតដល់ពេលដែលស្ថានភាពដីនោះត្រូវបានឯកភាពគ្នាជាមួយភាគីពាក់ព័ន្ធទាំងអស់ ហើយព្រំដែនរវាងដីឯកជន និងដីរបស់រដ្ឋត្រូវបានគូសកំណត់*។ " [...] " *នៅក្នុងកិច្ចដំណើរការធ្វើចំណាត់ថ្នាក់ដីនិងគូសកំណត់ព្រំដែនដី ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមនៅក្នុងកិច្ចដំណើរការមួយនៃការពិគ្រោះយោបល់សាធារណៈ ដើម្បីធានាឱ្យបាននូវការព្រមព្រៀងទូទៅជាមួយសេចក្តីសម្រេចចិត្តនានា*។ នៅក្នុងការវិនិច្ឆ័យជាប្រព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលដែលមានការបណ្តុះបណ្តាលឯកទេសលើការចូលរួមនឹងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកភូមិ ដោយពន្យល់អំពីនីតិវិធីផលិតឯកសារដីរបស់ភូមិ និង ធានាឱ្យបានថាសមាជិកទាំងអស់នៃសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលប័ណ្ណកម្មសិទ្ធិដី នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោង។" ឯកសារវាយតម្លៃគម្រោងក៏លើកឡើងផងដែរថា "គម្រោងក៏នឹងគាំទ្រផងដែរដល់ការអភិវឌ្ឍនីតិវិធី និងការអនុវត្តការរៀបចំផែនទីចំណាត់ថ្នាក់ដីនៅតាម*ខេត្តអនុវត្តគម្រោង* ដែលកំណត់ព្រំដែនដីរវាងប្រភេទផ្សេងៗនៃការប្រើប្រាស់ដី ដូចជា ទីក្រុង កសិកម្ម ព្រៃឈើ និង តំបន់ការពារ ជាដើម។ ការរៀបចំផែនទីទាំងនេះ នឹងត្រូវបានធ្វើតាមរយៈកិច្ចដំណើរការដោយមានការចូលរួមមួយនៅក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលមូលដ្ឋាន

អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិផ្សេងៗ ដើម្បីធានាឱ្យបាននូវកិច្ចការពារបរិស្ថាននិងជម្រកធម្មជាតិសមស្រប។" [ការគូសបញ្ជាក់ត្រូវបានបន្ថែម]

១១. ឃ្លាទាំងនេះមានន័យថាសមាសភាគគម្រោងមុខជាត្រូវបានអនុវត្តក្នុងលក្ខណៈសម្របសម្រួលគ្នា។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង សមាសភាគនីមួយៗនៃសមាសភាគទាំងនេះត្រូវបានអនុវត្តក្នុងល្បឿនខុសៗគ្នា។ ជាពិសេសសកម្មភាពខាងក្រោមនេះ ត្រូវបានពន្យារពេល ឬ មិនត្រូវបានអនុវត្ត[១០]:

ក. ក្រោមសមាសភាគទី (៣) យុទ្ធនាការព័ត៌មាននិងផ្សព្វផ្សាយ[១១] តាមរយៈអង្គការមិនមែនរដ្ឋាភិបាលដើម្បីជួយសហគមន៍ និង អ្នកមានសិទ្ធិដីធ្លីក្នុងការរៀបចំសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិនិងការចុះបញ្ជីសិទ្ធិរបស់ខ្លួនមិនត្រូវបានអនុវត្តទេ ដោយសារភាពស្ទាក់ស្ទើររបស់អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវជួលដោយរាជរដ្ឋាភិបាល និងបន្ទាប់មកទៀត ការយឺតយ៉ាវខាងលទ្ធកម្ម។

ខ. ក្រោមសមាសភាគទី (៤) យុទ្ធនាការផ្សព្វផ្សាយព័ត៌មានសាធារណៈជាប្រព័ន្ធនៅថ្នាក់មូលដ្ឋានអំពីយន្តការដោះស្រាយវិវាទ (DRM) នៅមិនទាន់បានចុះកិច្ចសន្យានៅឡើយជូនអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ។ ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលឯកទេសដែលត្រូវបានរំពឹងថាផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ "បុគ្គលនិងសហគមន៍ជួបការលំបាកដែលពាក់ព័ន្ធក្នុងវិវាទដីធ្លី" នៅមិនទាន់ត្រូវបានជួលនៅឡើយ[១២]។

គ. ក្រៅពីការរៀបចំប្រកាសស្តីពីការកំណត់និងការគូសផែនទីដីរបស់រដ្ឋ និង ការធ្វើចំណាត់ថ្នាក់ដីរបស់រដ្ឋដែលត្រូវបាន ផ្តល់ហិរញ្ញប្បទានក្រោមសមាសភាគទី ៥ សកម្មភាពសេសសល់ស្ទើរតែទាំងអស់ក្រោមសមាសភាគទី (៥) ត្រូវបានស្នើលុបចោល ហើយថវិកាសកម្មភាពទាំងនេះត្រូវបានស្នើសុំធ្វើវិភាជន៍ឡើងវិញ ដោយទទួលស្គាល់ថាការកំណត់ការគូសផែនទី និង សកម្មភាពចុះបញ្ជីដីខ្លះរបស់រដ្ឋ កំពុងត្រូវបានអនុវត្តតាមរយៈនីតិវិធីចុះបញ្ជីដី

---

[១០] សកម្មភាពផ្សេងៗដែលមានចែងនៅក្នុងបពារីនេះ ត្រូវបានផ្តួចផ្តើម ប៉ុន្តែ មិនត្រូវបានអនុវត្តយ៉ាងពេញលេញនិងប្រកបដោយប្រសិទ្ធភាព មិនត្រូវបានអនុវត្តតែម្តង ឬ មិនត្រូវបានអនុវត្តនិងត្រូវបានស្នើសុំដកចេញ។

[១១] បេសកកម្មសិក្សាវាយតម្លៃ បានដឹងថាសកម្មភាពផ្សព្វផ្សាយព័ត៌មានតាមយរៈក្រុមនានារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានអនុវត្តក្រោមគម្រោង LMAP។ ប៉ុន្តែ កិច្ចប្រឹងប្រែងទាំងនេះមិនមែនមានន័យ និង មិនបានបំពេញគោលដៅដូចគ្នានឹងគោលដៅទាំងឡាយដែលត្រូវបានគ្រោងកាលពីដើមដំបូងថាត្រូវអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល។ មូលហេតុនៃការខ្វះខាតការអនុវត្តសកម្មភាពទាំងនេះ ត្រូវបានយល់យ៉ាងពេញលេញដោយបេសកកម្មសិក្សាវាយតម្លៃ ប៉ុន្តែ ទំនាក់ទំនងរវាងការខ្វះខាតការអនុវត្តនេះ និង ផលវិបាកលើសហគមន៍ទាំងឡាយដែលសុំប័ណ្ណកម្មសិទ្ធិដី និង សុវត្ថិភាពនៃការកាន់កាប់ គឺមានលក្ខណៈគួរឱ្យកត់សម្គាល់។

[១២] គេគប្បីលើកឡើងថាតាមបេសកកម្មត្រួតពិនិត្យចុងក្រោយ ករណីវិវាទដីធ្លីជាង ១៩៧៦ ករណីនៅត្រូវរង់ចាំការដោះស្រាយ ហើយប្រសិនបើអ្នកទាមទារសិទ្ធិដីធ្លីមិនត្រូវបានផ្តល់ព័ត៌មានសមស្របនិងត្រូវបានជួយដោយអ្នកច្បាប់មានសមត្ថភាពទេនោះ ពួកគេប្រហែលជាមិនអាចទប់ទល់និងការពារករណីរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ទេនៅចំពោះមុខគណៈកម្មការសុរិយោដី រួមទាំងគណៈកម្មការសុរិយោដីចល័តដែលត្រូវបានបង្កើតឡើងដើម្បីពន្លឿនដំណោះស្រាយវិវាទនៅតាម "តំបន់មានវិវាទដីធ្លីក្តៅ"។

ជាប្រព័ន្ធនិងក្រៅប្រព័ន្ធ (ក្រោមសមាសភាគទី ៣) ...។"[១៣] គេឃើញមានការលើកឡើងផងដែរថាសកម្មភាពនៅសល់នៃសមាសភាគនេះនឹងត្រូវបានអនុវត្តក្រោយពេលដែលមានគោលនយោបាយវិស័យគ្រប់គ្រងដីធ្លី និងការអនុម័តកម្មវិធីពាក់ព័ន្ធមួយ។

១២. ដោយសារការមិនអនុវត្តសមាសភាគនិងសកម្មភាពដែលបានរាយបញ្ជីខាងលើនេះ គម្រោងបានងាកចេញពីគ្រោងការណ៍ដំបូងរបស់វាដែលត្រូវបានអធិប្បាយនៅក្នុងឯកសារវាយតម្លៃគម្រោង និងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ថាជាអភិក្រមពហុមុខព្រួញមួយ ដើម្បីដោះស្រាយបញ្ហាដីធ្លីឱ្យបានពេញលេញនៅកម្ពុជា[១៤]។ បេសកកម្មសិក្សាវាយតម្លៃ បាន រកឃើញថាសមាសភាគនិងសកម្មភាពនានាដែលត្រូវបានកំណត់និងប្រទាក់ក្រឡាគ្នាយ៉ាងល្អនៃគម្រោង LMAP ត្រូវបានផ្តាច់ចេញពីគ្នា ដោយការអនុវត្តផ្តោតលើផ្នែកដែលមានជោគជ័យច្រើនជាងគេ (ការបណ្តុះបណ្តាល ការងារសំណង់ និង ការផ្តល់ប័ណ្ណកម្មសិទ្ធិ និង ការចុះបញ្ជីដីគ្មានវិវាទ ក៏ដូចជាវឌ្ឍនភាពក្នុងការលើកកម្ពស់និងអភិវឌ្ឍន៍បន្ថែមទៀតនូវគោលនយោបាយដីធ្លី និងក្របខ័ណ្ឌគតិយុត្តិ រួមទាំងគោលនយោបាយនិងលិខិតបទដ្ឋាននានា) ខណៈដែលមិនអនុវត្តសកម្មភាពផ្សេងទៀត ដែលអាចជួយសម្រេចបានយ៉ាងពេញលេញនូវគោលដៅអភិវឌ្ឍន៍នៃគម្រោង LMAP ដើម្បីលើកកម្ពស់សុវត្ថិភាពដី។ ចំពោះមុខការខិតជិតមកដល់នៃកាលបរិច្ឆេទបិទគម្រោង វាគឺជាកិច្ចការបន្ទាន់ដែលត្រូវអនុវត្តសកម្មភាពឱ្យបានច្រើនតាមដែលអាចធ្វើបាន ដែលស្របគ្នាជាមួយគម្រោងដូចដែលត្រូវបានគ្រោងតាំងពីដើមដំបូង។ ប៉ុន្តែ ប្រសិនបើ ធនាគារពិភពលោកនឹងបន្តចូលរួមក្នុងវិស័យដីធ្លីនៅកម្ពុជាក្រោយឆ្នាំ២០១០ ការពិនិត្យវាយតម្លៃដ៏ហ្មត់ចត់មួយគឺចាំបាច់ដើម្បីជូនព័ត៌មាន ដល់ថ្នាក់គ្រប់គ្រងអំពីស្ថានភាពវិស័យដីធ្លីជារួម និងការពិភាក្សាគោលនយោបាយពាក់ព័ន្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា[១៥]។

***<u>សំណួរទី ២:</u>*** ***<u>តើសេចក្តីសម្រេចចិត្តនៃការរៀបចំក្នុងការមិនដាក់បញ្ចូលតំបន់ទាំងឡាយ ដែលមានវិវាទលើការកាន់កាប់ដីធ្លីមានលក្ខណៈសមស្របឬទេ ចំពោះមុខការឡើងថ្លៃដី ការបង្កើនល្បឿននៃការតាំងលំនៅឋានថ្មី និងការអនុម័តការបណ្តេញចេញដោយបង្ខំដោយរាជរដ្ឋាភិបាល?</u>***

១៣. មូលហេតុនៃការសម្រេចមិនដាក់បញ្ចូលដីមានវិវាទ ត្រូវបានលើកឡើងនៅក្នុងឯកសារវាយតម្លៃគម្រោង: "ការធ្វើចំណាត់ថ្នាក់ដីនិងការគូសកំណត់ព្រំដែនដីរវាងដីសាធារណៈនិងដីឯកជន [.....] ច្រើនតែមានលក្ខណៈពិបាក និងអាចបង្កើនវិវាទនៅក្នុងរយៈពេលខ្លី"។ ចំណុចនេះត្រូវបានទទួលស្គាល់ថាគឺជាសក្តានុពល "ទិដ្ឋភាពចម្រូងចម្រាស់" មួយនៅក្នុងឯកសារវាយតម្លៃគម្រោង (ទំព័រ ២៤) ដែលចែងយ៉ាងច្បាស់លាស់ថា "គម្រោងនឹងមិនផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅតាមតំបន់ទាំងឡាយ ដែលនៅទីនោះទំនងជាមានវិវាទ រហូតដល់ពេលមានកិច្ចព្រមព្រៀងគ្នាអំពីស្ថានភាពដី។ គម្រោងនឹងគាំទ្រកិច្ចដំណើរការពិគ្រោះយោបល់សាធារណៈ ដើម្បីជួយស្ថាបនាការស្រុះស្រួលគ្នាសម្រាប់

[១៣] ឯកសារជំនួយស្មារតី (បេសកកម្មត្រួតពិនិត្យទី ១១ ខែ មករា ឆ្នាំ ២០០៩) ទំព័រ ១១-១២។

[១៤] សូមមើលតារាងនៅក្នុងឧបសម្ព័ន្ធ ១។

[១៥] ការពិនិត្យវាយតម្លៃនេះប្រហែលជាអាចជួយផងដែរក្នុងការរៀបចំឯកសារយោងការងារសម្រាប់របាយការណ៍បញ្ចប់ការអនុវត្ត (ICR) សម្រាប់ការដកស្រង់បទពិសោធន៍។

សេចក្ដីសម្រេចចិត្តនានា និង នឹងធានាឱ្យបាននូវការពិភាក្សានិងការពិគ្រោះយោបល់ជាបន្តជាមួយអង្គការមិនមែនរដ្ឋាភិបាល និង សង្គមស៊ីវិល។ គេបានរំពឹងថាដីមួយចំនួនដែលនៅពេលនេះជានាមស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ (ប្រហែល ៨០% នៃផ្ទៃដីសរុប) នឹងត្រូវបានប្រគល់ជូនផ្នែកឯកជន។ ប្រការនេះនឹងធ្វើរាជរដ្ឋាភិបាលមានធនធានដើម្បីគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងនូវផ្ទៃដីទាំងឡាយដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន។"

១៤. សកម្មភាពរបស់អាជ្ញាធររាជធានីដែលផ្ដោតលើសិទ្ធិដីធ្លីនៃដីដែលមានតម្លៃបំផុត ដូចដែលត្រូវបានបង្ហាញភស្តុតាងដោយរបាយការណ៍នានានៃសារព័ត៌មាន និង/ឬ អង្គការមិនមែនរដ្ឋាភិបាល អំពីការបណ្ដេញចេញពីដី និង/ឬ កង្វះខាតការអនុវត្តសកម្មភាពផ្ដល់ប័ណ្ណកម្មសិទ្ធិ តាមសំណើជាក់លាក់ពីសហគមន៍ កំពុងចោទជាបញ្ហាប្រឈមមួយចំពោះអភិក្រមនៃគម្រោង LMAP ចំពោះការផ្ដល់ប័ណ្ណកម្មសិទ្ធិ ការចុះបញ្ជី និងការគ្រប់គ្រងដី និងត្រូវបានចាត់ទុកដោយអង្គការមិនមែនរដ្ឋាភិបាល និង មេដឹកនាំសហគមន៍ ថាជាបរាជ័យនៃគម្រោង LMAP ដែលមិនមានលទ្ធភាពឆ្លើយតបនិងដោះស្រាយបញ្ហាទាំងនេះប្រកបដោយប្រសិទ្ធភាព ខណៈដែលរាជរដ្ឋាភិបាលកំពុងចាត់ទុកបញ្ហាទាំងនេះថាជាបញ្ហាដោយឡែកនៅក្រៅវិសាលភាពនៃគម្រោង LMAP[១៦]។

១៥. បេសកកម្មសិក្សាវាយតម្លៃបានសន្និដ្ឋានថាថ្វីបើការមិនដាក់បញ្ចូលតំបន់ដែលមានទំនាស់កាន់កាប់ដីនៅក្នុងកិច្ចដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិនិងចុះបញ្ជីរហូតដល់ពេលដែលនីតិវិធីសមស្របមួយត្រូវបានអនុវត្តដើម្បីធ្វើចំណាត់ថ្នាក់និងគូសកំណត់ព្រំដែននៃដីប្រភេទផ្សេងៗគឺជាសេចក្ដីសម្រេចចិត្តដ៏ល្អមួយក្ដី ក៏លក្ខណៈវិនិច្ឆ័យនិងនីតិវិធីគូសកំណត់ព្រំដែនដីពុំត្រូវបានអនុវត្តទេ ទោះបីជាត្រូវបានកំណត់ក្រោមប្រកាសស្ដីពីការកំណត់និងការគូសផែនទីដីរបស់រដ្ឋ និង ការធ្វើចំណាត់ថ្នាក់ដីរបស់រដ្ឋ ដែលត្រូវបានគាំទ្រដោយសមាសភាគទី ៥ ក្ដី ដែលបណ្ដាលឱ្យមានអវត្តមាននៃការគូសផែនទីដីផ្លូវការរបស់រដ្ឋ។ ចំណុចនេះគឺជាប្រភពនៃការបារម្ភដ៏ធំមួយសម្រាប់អ្នកទាំងឡាយដែលស្ថិតនៅក្រោមការគម្រាមកំហែងនៃការបណ្ដេញចេញ ដោយសារចំពោះមុខអវត្តមាននៃផែនទីទាំងនេះ អាជ្ញាធរសាលាក្រុងពាក់ព័ន្ធអាចមិនដាក់បញ្ចូលក្នុងការផ្ដល់ប័ណ្ណកម្មសិទ្ធិនូវដីមួយផ្នែកណាដែលត្រូវបានពិនិត្យមើលនិងស្នើឡើងសម្រាប់ការវិនិច្ឆ័យដោយក្រុមសុរិយោដី និង ការចេញប័ណ្ណកម្មសិទ្ធិដីនោះ ក្នុងនាមរបស់រដ្ឋ។ តាមពិត អវត្តមាននៃការគូសផែនទីដីរបស់រដ្ឋត្រូវបានកំណត់ថាជាចំណុចខ្វះខាតដ៏សំខាន់មួយដែលចាំបាច់ត្រូវដោះស្រាយដើម្បីឱ្យគម្រោង LMAP បានទទួលជោគជ័យ និង ជួយដោះស្រាយវិវាទដីធ្លី និង សុវត្ថិភាពនៃការកាន់កាប់[១៧]។ ហេតុដូច្នេះ វាប្រហែលគឺជាសេចក្ដី

---

[១៦] សូមមើលលេខយោង ១៧។

[១៧] រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ចែងថា: "សិទ្ធិដកហូតអចលនទ្រព្យពីជនណាម្នាក់ នឹងត្រូវបានអនុវត្តតែដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះដូចដែលមានចែងក្នុងច្បាប់ និង ត្រូវតម្រូវឱ្យមានការផ្ដល់សំណងប្រកបដោយយុត្តិធម៌និងត្រឹមត្រូវជាមុន" (មាត្រា ៤៤)។ ប៉ុន្តែ តាមការពិត ស្ថានភាពជាក់ស្ដែងចោទជាបញ្ហាប្រឈមធ្ងន់ធ្ងរពីរចំពោះការអនុវត្តច្បាប់ និង បណ្ដាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះប្រជាជនពាក់ព័ន្ធ។ ទីមួយ ប្រជាជនភាគច្រើនមានតែសិទ្ធិកាន់កាប់ប៉ុណ្ណោះចំពោះដីរបស់ខ្លួន ហើយការកំណត់ព្រំដែនដីប្រភេទផ្សេងៗមិនត្រូវបានធ្វើជាក់ស្ដែងទេ។ ហេតុដូច្នេះ ប្រជាជនអាចមិនដឹងទេអំពីដីប្រភេទអ្វីដែលពួកគេកំពុងកាន់កាប់។ ការកំណត់ថាតើពួកគេមាន "កម្មសិទ្ធិស្របច្បាប់"លើដីឬទេសម្រាប់គោលបំណងផ្ដល់សំណង អាចគឺជាបញ្ហាប្រឈមដ៏ធំមួយ។ ទីពីរ ដីចំណីផ្លូវត្រូវបានចាត់ទុកជាដីសាធារណៈរបស់

សម្រេចចិត្តដ៏ល្អមួយនៅពេលរៀបចំគម្រោងដែលផ្តោតលើតំបន់គ្មានវិវាទនិងការតវ៉ាសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ។ នៅពេលនេះ យុទ្ធសាស្ត្រនេះគប្បីត្រូវបានពិនិត្យមើលនិងកែសម្រួលឡើងវិញ ចំពោះមុខគោលដៅអភិវឌ្ឍន៍នៃគម្រោង LMAP ក្នុងការលើកស្ទួយសុវត្ថិភាពដី[១៨] ។

១៦. គេគប្បីកត់សម្គាល់ថាកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ មិនមាននិយាយយោងដល់ការជួយគាំទ្រដល់ប្រតិបត្តិការផ្តល់ប័ណ្ណកម្មសិទ្ធិនិងការចុះបញ្ជីដីនៅតាមតំបន់គ្មានវិវាទ និង/ឬ តំបន់គ្មានការតវ៉ាឡើយ។ ផ្ទុយទៅវិញ ឯកសារនេះនិយាយអំពីខេត្តអនុវត្តគម្រោងថាជាតំបន់សម្រាប់ការអនុវត្តសកម្មភាពផ្តល់ប័ណ្ណកម្មសិទ្ធិនិងចុះបញ្ជីដី។ ដោយសារមូលហេតុនេះ វាគឺជាប្រការសំខាន់ដែលរាជរដ្ឋាភិបាលចាំបាច់ត្រូវប្តេជ្ញាចំពោះការគាំទ្រដល់ការចុះបញ្ជីដី ការផ្តល់ប័ណ្ណកម្មសិទ្ធិ និង គោលនយោបាយនិងនីតិវិធីវិនិច្ឆ័យ រវាងសកម្មភាពដែលទទួលហិរញ្ញប្បទាញពីគម្រោង LMAP និងសកម្មភាពខេត្ត/រាជធានីនៅក្នុងខេត្តអនុវត្តគម្រោង ដោយសារ គម្រោង LMAP គ្របដណ្តប់លើដីទាំងអស់នៅក្នុងខេត្តអនុវត្តគម្រោង ដូចដែលត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍។

***សំណួរទី ៣: តើការតាំងលំនៅឋានថ្មីនៅក្នុងសហគមន៍ទាំងឡាយដែលចូលរួមក្នុងគម្រោង LMAP ត្រូវបានចាត់ចែងតាមវិធីមួយដែលស្របគ្នាជាមួយនឹងក្របខ័ណ្ឌគោលនយោបាយតាំងលំនៅឋានថ្មីដែលត្រូវបានរៀបចំសម្រាប់គម្រោងនេះ និង គោលនយោបាយការពាររបស់ធនាគារពិភពលោក ដែលត្រូវអនុវត្តចំពោះគម្រោងឬទេ?***

១៧. ឯកសារវាយតម្លៃគម្រោង ចែងយ៉ាងច្បាស់ថាៈ "កិច្ចព្រមព្រៀងត្រូវបានឈានដល់ជាមួយក្រសួង (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់) ទាក់ទិននឹងអភិក្រមដែលត្រូវប្រើនៅក្នុងករណីនៃអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ រួមទាំងអ្នកតាំងលំនៅឋានអនាធិបតេយ្យ។ គម្រោងនេះ: (ក) នឹងចេញប័ណ្ណកម្មសិទ្ធិដីនៅទីណាដែលមានការយល់ព្រមពីរាជរដ្ឋាភិបាលក្នុងការផ្តល់ដី ដែលត្រូវចុះបញ្ជីជូនដល់អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ (ខ) នឹងជួយសម្រួលការផ្តល់សេវានិងការផ្តល់ប័ណ្ណកម្មសិទ្ធិនៅទីណាដែលសាលាក្រុងកំពុងធ្វើការជាមួយក្រុមអភិវឌ្ឍន៍នានាដើម្បីផ្តល់ដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋានផ្អែកលើគោលការណ៍

---

រដ្ឋ។ ប្រជាជនជាច្រើនកាន់កាប់ដីចំណីផ្លូវដោយសុទ្ធចិត្ត និង ប្រហែលជាមិនដែលត្រូវបានគេប្រាប់ទេអំពីស្ថានភាព "ខុសច្បាប់" របស់ខ្លួន។ ប៉ុន្តែ ច្បាប់ភូមិបាល (មាត្រា ១៨) ហាមឃាត់មិនឱ្យកម្មសិទ្ធិដី "ខុសច្បាប់" ត្រូវបានធ្វើឱ្យក្លាយទៅជាស្របច្បាប់ឡើយ។ ចំណុចនេះអាចចោទជាបញ្ហាដ៏ធំសម្រាប់ប្រជាជនដែលកាន់កាប់ដីចំណីផ្លូវ ប្រសិនបើដីចំណីផ្លូវត្រូវបានអនុវត្តស្របតាមសេចក្តីចែងនៃច្បាប់នេះ។

[១៨] ថ្វីបើឯកសារវាយតម្លៃគម្រោងពិតជាមានការលើកឡើងខ្លះអំពីការមិនដាក់បញ្ចូលក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិនិងការចុះបញ្ជីនូវ "ដីមានវិវាទ" ក្តី ក៏ឯកសារនេះមិនផ្តល់លក្ខណៈវិនិច្ឆ័យឬនិយមន័យអំពីរបៀបកំណត់អត្តសញ្ញាណដីប្រភេទនេះ សំដៅមិនរាប់បញ្ចូលដីទាំងនេះនៅក្នុងកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ (សូមមើលឧបសម្ព័ន្ធ ២)។ ឯកសារវាយតម្លៃគម្រោង នៅក្នុងផ្នែកសំខាន់ៗមួយចំនួន (ឧបសម្ព័ន្ធស្តីពីសេចក្តីអធិប្បាយលម្អិតអំពីគម្រោង) និង កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ (តារាង ៦) និយាយដល់ការអនុវត្តគម្រោង រួមទាំងការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធនៅក្នុងខេត្តអនុវត្តគម្រោង ដោយមិនមាននិយាយយោងដល់ការមិនដាក់បញ្ចូលដីមានវិវាទទេ។

នៃមជ្ឈមណ្ឌលសហប្រជាជាតិសម្រាប់ការតាំងលំនៅឋានមនុស្ស (UNCHS)[១៩] និង (គ) នឹងមិនចេញប័ណ្ណកម្មសិទ្ធិទេនៅទីណាដែលពុំមានកិច្ចព្រមព្រៀងក្នុងការបែងចែកដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ ឬ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋាន។ គម្រោងបានរៀបចំនីតិវិធីសម្រាប់ពិនិត្យចម្រាញ់ និង សម្រាប់ការពិគ្រោះយោបល់ដើម្បីធានាឱ្យបានថាល័ក្ខខ័ណ្ឌខាងលើនេះត្រូវបានឯកភាពគ្នាមុនពេលផ្តល់សេវាចុះបញ្ជីនិងផ្តល់ប័ណ្ណកម្មសិទ្ធិដី។" [...] ។ ក្របខ័ណ្ឌការពារសម្រាប់គម្រោង LMAP ក៏ត្រូវបានរៀបចំស្របតាមគំនិតនេះដែរ។

១៨. ក្របខ័ណ្ឌការពារនៃគម្រោង LMAP មិនត្រូវបានសាកល្បងទេដោយសារសេចក្តីសម្រេចចិត្តដែលត្រូវបានពិភាក្សាខាងលើថាមិនអនុវត្តសកម្មភាពផ្តល់ប័ណ្ណកម្មសិទ្ធិនៅក្នុង "តំបន់មានវិវាទ" ឬ សម្រាប់ "ដីមានវិវាទ"[២០] ។ "នីតិវិធីសម្រាប់ពិនិត្យចម្រាញ់និងសម្រាប់ការពិគ្រោះយោបល់" មិនត្រូវបានរៀបចំទេ ហើយបេសកកម្មសិក្សាវាយតម្លៃបានរកឃើញថាក្នុងករណីទាំងឡាយដែលអាជ្ញាធរសាលាក្រុងពាក់ព័ន្ធបានសម្រេចចិត្តប្រើជម្រើសមិនផ្តល់ប័ណ្ណកម្មសិទ្ធិ និងចុះបញ្ជីដីទាំងឡាយ ដែលត្រូវបានកាន់កាប់ដោយអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ កិច្ចការពារមិនត្រូវបានអនុវត្តទេ រួមទាំងគោលការណ៍អង្គការ UNCHS[២១] ។

១៩. សេចក្តីណែនាំសម្រាប់នីតិវិធីចុះបញ្ជីដីជាប្រព័ន្ធដែលត្រូវបានរៀបចំក្រោមគម្រោង LMAP[២២] ចែងពីករណីយកិច្ចត្រូវពិនិត្យមើល រៀបចំកិច្ចប្រជុំជាមួយអ្នកកាន់កាប់ដី ភោគី ឬ អ្នកប្រើប្រាស់ និង អនុញ្ញាតឱ្យពួកគេដាក់ពាក្យតវ៉ា និងបដិសេធលទ្ធផលនៃការពិនិត្យមើលនៅក្នុងដំណាក់កាលដាក់តាំងផ្សាយជាសាធារណៈ មុនពេលដែលគណៈកម្មការរដ្ឋបាលរៀបចំរបាយការណ៍ស្ថាពរសម្រាប់គោលបំណងនៃបញ្ជាចុះបញ្ជី។ កង្វះខាតការអនុវត្តសមាសភាគទី (៣) "អនុវត្តយុទ្ធនាការព័ត៌មាននិងផ្សព្វផ្សាយតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយសហគមន៍ និង អ្នកកាន់កាប់សិទ្ធិដីធ្លីក្នុងការរៀបចំសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិ និងការចុះបញ្ជីនៃសិទ្ធិរបស់ពួកគេ" និង សមាសភាគទី (៤) ផ្តល់ជំនួយផ្នែកច្បាប់ជូនដល់បុគ្គល និងសហគមន៍ជួបការលំបាកដែលពាក់ព័ន្ធក្នុងវិវាទដីធ្លី តាមរយៈអង្គការមិនមែនរដ្ឋាភិបាលឯកទេស បានធ្វើឱ្យកិច្ចដំណើរការនេះមិនសូវមានលក្ខណៈចូលរួមនិងមិនសូវមានតម្លាភាពសម្រាប់

---

[១៩] កម្មវិធីអង្គការ UNCHS គឺផ្អែកលើគោលការណ៍អន្តរជាតិសម្រាប់ទីម្រុក ពោលគឺ (ក) ផ្តល់សុវត្ថិភាពនៃការកាន់កាប់ (ខ) ជម្រុញសិទ្ធិមានលំនៅឋានគ្រប់គ្រាន់ (គ) ផ្តល់លទ្ធភាពស្មើគ្នាក្នុងការទទួលដីធ្លី (ឃ) ជម្រុញលទ្ធភាពស្មើគ្នាក្នុងការទទួលឥណទាន និង (ង) ជម្រុញលទ្ធភាពទទួលសេវាកម្មនិងគោលការណ៍ណែនាំជាមូលដ្ឋាននានា។ សេចក្តីអធិប្បាយនៃកម្មវិធីអង្គការ UNCHS ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយធនាគារពិភពលោកនៅក្នុងឯកសារព័ត៌មានគម្រោង (PID) LMAP ។

[២០] វាគឺជាប្រការមានប្រយោជន៍ដែលត្រូវអនុវត្តការប្រុងប្រយ័ត្នសមស្របពេញលេញមួយលើករណីនានាដែលត្រូវបានដាក់ជូនគណៈកម្មការសុរិយោដីស្របតាមយន្តការដោះស្រាយវិវាទ ដើម្បីពិនិត្យមើលករណីទាំងឡាយដែលអ្នកទាមទារដីត្រូវបានបដិសេធសំណើរបស់ខ្លួនដើម្បីសុំប័ណ្ណកម្មសិទ្ធិ និង អ្វីដែលគឺជាផលវិបាកទាក់ទិននឹងការអនុវត្តកិច្ចការពារ។ ថ្វីបើស្ថិតិអំពីករណីវិវាទដីធ្លីត្រូវបានលើកឡើងក្តី ក៏គេពុំឃើញមានឯកសាររកបានដោយងាយស្តីពីធាតុពិតនៃវិវាទទាំងនេះ ឬ ឯកសារស្តីពីការប្រតិបត្តិសេចក្តីសម្រេចចិត្តរបស់គណៈកម្មការសុរិយោដី។

[២១] សូមមើលលេខយោង ១៧។

[២២] សេចក្តីនែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦។

សហគមន៍ងាយរងគ្រោះបំផុតដែលសុំការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅក្នុងតំបន់មួយដែលត្រូវវិនិច្ឆ័យនៅ ក្នុងតំបន់ទីក្រុង ជាពិសេសនៅរាជធានីភ្នំពេញ។

២០. បេសកកម្មសិក្សាវាយតម្លៃ បានចុះពិនិត្យមើលតំបន់ដែលស្ថិតនៅជិតប្រឡាយទឹកស្អុយមួយ និង បានពិភាក្សាជាមួយក្រុមគម្រោង LMAP និង អាជ្ញាធរសាលាក្រុងអំពីករណីជាក់លាក់នៃតំបន់នេះ ដែលត្រូវបានចុះពិនិត្យមើលសម្រាប់គោលបំណងនៃការវិនិច្ឆ័យដោយក្រុមសុរិយោដី។ ប៉ុន្តែ ក្រោយពេលដែលគណៈកម្មការរដ្ឋបាលត្រូវបានបង្កើតឡើង មានតែផ្នែកខ្លះនៃតំបន់នេះប៉ុណ្ណោះដែលត្រូវបានវិនិច្ឆ័យ ហើយពុំមានការផ្តល់ការពន្យល់ឬមូលហេតុអ្វីជូនដល់ភោគីអំពីការកាត់ដីរបស់ពួកគេចេញពីការវិនិច្ឆ័យនេះ។ ក្រុមបេសកកម្មមិនទទួលបានព័ត៌មានអ្វីទៀតទេអំពីការដកចេញនេះ ។ បេសកកម្មសិក្សាវាយតម្លៃ ក៏បានពិភាក្សាផងដែរជាមួយតំណាង របស់សាលាក្រុងថាតើផែនការសកម្មភាពតាំងលំនៅឋានថ្មីមួយនឹងត្រូវបានអនុវត្តឬទេ សម្រាប់ភោគីដីទាំងឡាយ ដែលមិនត្រូវបានគេរកឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ពុំមានការផ្តល់ចម្លើយទេ ក្រៅពីការនិយាយថាករណីនេះត្រូវបានចាត់ចែងនៅក្រៅសមត្ថកិច្ចនៃគម្រោង LMAP និងត្រូវបានកំណត់ថា ជាប់ទាក់ទិននឹងដីមានវិវាទ (ពោលគឺ ដីរបស់រដ្ឋ)។ បេសកកម្មសិក្សាវាយតម្លៃ យល់ថាចំណុចនេះគឺជាឧទាហរណ៍ដ៏ ច្បាស់លាស់មួយដែលការអនុវត្តសកម្មភាពផ្សព្វផ្សាយនិងជំនួយផ្នែកច្បាប់អាចជួយជនរងផលប៉ះពាល់ក្នុងការទាមទារសិទ្ធិរបស់ខ្លួន ការតវ៉ាចំពោះលទ្ធផលនៃកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិនិងការចុះបញ្ជី និង ការទទួលបានអត្ថប្រយោជន៍ពីគោលការណ៍ណែនាំផ្នែកបរិស្ថាន និង សង្គមកិច្ច តាមភាពសមស្រប។

***សំណួរទី ៤: តើធនាគារពិភពលោកបានខកខានមិនបានស៊ើបមើលលើការចោទប្រកាន់អំពីការបំពាននៅក្នុងការអនុវត្តច្បាប់ភូមិបាល និង មិនបានលើកឡើងអំពីការចោទប្រកាន់ទាំងនេះជូនរាជរដ្ឋាភិបាល ឬទេ?***

២១. បេសកកម្មសិក្សាវាយតម្លៃ បានរកឃើញថារដ្ឋបាលសុរិយោដី តាមរយៈគម្រោង LMAP ធ្វើការពិនិត្យមើលជាមូលដ្ឋានមួយ និង ផ្តល់អនុសាសន៍ជូនសាលាក្រុង ឬ ស្រុកពាក់ព័ន្ធដើម្បីអនុវត្តកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ។ ដោយសារការសន្មតថា ដីមានវិវាទទាំងឡាយនឹងមិនត្រូវបានពិនិត្យនិងចេញប័ណ្ណកម្មសិទ្ធិជូន អាជ្ញាធរសាលាក្រុងពាក់ព័ន្ធបានអនុវត្តសិទ្ធិឯកតោភាគីក្នុងការកាត់ចេញនូវដីដែលបានពិនិត្យមើលដោយរដ្ឋបាលសុរិយោដី។ ដោយធ្វើដូច្នេះ សាលាក្រុងបានសម្រេចមិនអនុវត្តការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធជូនដល់តំបន់ដែលត្រូវបានកាត់ចេញ។ ម្យ៉ាងទៀត ចំពោះប្រជាជនទាំងឡាយដែលរងផលប៉ះពាល់ដោយសេចក្តីសម្រេចចិត្តកាត់ដីដែលពួកគេស្នាក់នៅចេញពីតំបន់ដែលត្រូវវិនិច្ឆ័យ គេពុំឃើញមានការអនុវត្តកិច្ចការពារសង្គមកិច្ចឡើយ។ ប្រជាជនរងផលប៉ះពាល់ដែលត្រូវបានសម្ភាសន៍ដោយបេសកកម្មសិក្សាវាយតម្លៃ បាននិយាយថាពុំមានការពិគ្រោះយោបល់ ឬ ការផ្តល់ព័ត៌មានជូនពួកគាត់ទេ មុនពេលសម្រេចចិត្តកាត់តំបន់មួយចេញពីការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ ហើយពុំមានការផ្តល់ជំនួយផ្នែកច្បាប់ជូនដល់ពួកគាត់ទេក្នុងការដាក់ពាក្យតវ៉ាផ្អែកលើមូលដ្ឋាននៃសិទ្ធិនៃកម្មសិទ្ធិរបស់ពួកគេ និង សិទ្ធិរបស់ពួកគេចំពោះការផ្តល់សំណងដែលអាចមាន ឬ ជំនួយក្នុងការតាំងលំនៅឋានថ្មី។

២២. គ្រោងការណ៍រួមនៃកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ សន្មតថាតំបន់ភូមិសាស្ត្រដំបូងដែលត្រូវវិនិច្ឆ័យ និងទទួលការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ គប្បីត្រូវបានគូសផែនទីនៅក្នុងតំបន់ភូមិសាស្ត្រនោះទាំងមូល ដោយចង្អុលបង្ហាញក្បាលដីមានស្រាប់ទាំងអស់និងការប្រើប្រាស់ដីទាំងនោះបច្ចុប្បន្ន តាមវិធីចូលរួម។ ចំណុចនេះនឹងផ្តល់ការរៀបចំឯកសារមួយអំពីការប្រើប្រាស់ដីមានស្រាប់នៅក្នុងថ្ងៃចុះពិនិត្យមើលដី។ សិទ្ធិរបស់អ្នកប្រើប្រាស់ ភោគី អ្នកជួល ត្រូវតែត្រូវបានពិនិត្យមើលនិងចងក្រងជាឯកសារឱ្យបានសមស្រប។ ប្រសិនបើត្រូវបានធ្វើដូច្នេះ នោះពុំមានការកំណត់ដីរបស់រដ្ឋជាក់ស្តែងត្រូវបានធ្វើដោយការកាត់តំបន់នានាចេញពីតំបន់វិនិច្ឆ័យណាមួយទោះបីជាត្រូវបានបញ្ជាដោយសាលាខេត្ត/សាលាក្រុង ឬ ត្រូវបានកំណត់ផ្សេងពីនេះក្តី។ ការធានាឱ្យបានថាកិច្ចដំណើរការ ដែលត្រូវបានអនុវត្តដោយអាជ្ញាធរដើម្បីកាត់ឬដាក់នៅខាងក្រៅនូវដីមួយផ្នែកចេញពីតំបន់ផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធគឺមានតម្លាភាព មានលក្ខណៈជាសាធារណៈ និង ត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយ គឺជាការសន្មតដ៏សំខាន់មួយដែលមានមូលដ្ឋានរឹងមាំផ្អែកលើច្បាប់ជាធរមាន ដែលត្រូវបានគាំទ្រដោយគម្រោង LMAP[២៣]។ ការកំណត់ដីរបស់រដ្ឋ (សាធារណៈនិងឯកជន) គប្បីត្រូវបានកំណត់មុនពេលឬស្របពេលគ្នានឹងការផ្តល់ប័ណ្ណកម្មសិទ្ធិដីបុគ្គល។ ចំណុចនេះ មិនបានកើតឡើងទេនៅតំបន់ទីក្រុងមកដល់ពេលនេះ ដែលគឺជាមូលហេតុដែលអាជ្ញាធរខេត្ត/រាជធានីកំពុងព្យាយាម កំណត់ថាតើអ្វីគឺជាដីរបស់រដ្ឋ និង សុំឱ្យកាត់ដីនោះចេញពីកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ។ ការកំណត់និងការគូសផែនទីដីរបស់រដ្ឋ (សាធារណៈនិងឯកជន) មិនត្រូវធ្វើតាមរយៈការកាត់ជាឯកតោភាគីទេ ពោលគឺ កិច្ចការនេះត្រូវធ្វើនៅក្នុងកិច្ចដំណើរការដោយឡែកមួយដែលមានតម្លាភាពនិងការចូលរួមដូចដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិគតិយុត្តិនិងនិយ័តកម្មពាក់ព័ន្ធនានា[២៤]។

---

[២៣] បេសកកម្មសិក្សាវាយតម្លៃយល់ការកាន់កាប់ឬកម្មសិទ្ធិដីដែលបានចាប់ផ្តើមក្រោយពេលអនុម័តច្បាប់ភូមិបាល (ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១) គឺខុសច្បាប់ និង អាចផ្តល់មូលហេតុឱ្យអាជ្ញាធរមានសមត្ថកិច្ចចេញបទបញ្ជាបណ្តេញចេញជូនអ្នកកាន់កាប់ឬភោគីដើម្បីឱ្យចេញពីដី។ ប៉ុន្តែ ស្ថានភាពគឺខុសគ្នាសម្រាប់អ្នកកាន់កាប់ឬភោគីដែលទាមទារកម្មសិទ្ធិ និង ប្រើប្រាស់ដីមុនថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលអាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធឬក្រៅប្រព័ន្ធ។

[២៤] ការពិនិត្យវាយតម្លៃកិច្ចការពារ (Safeguard Review) (គ្មានចុះកាលបរិច្ឆេទ) លើផលប័ត្រធនាគារពិភពលោកនៅកម្ពុជា បានផ្តល់នូវអ្វីដែលអាចផ្តល់ការពន្យល់មួយអំពីសកម្មភាពរបស់សាលាក្រុងរាជធានីភ្នំពេញក្នុងការកាត់ដីចេញពីតំបន់នានាដែលត្រូវបានរក្សាទុកសម្រាប់ការវិនិច្ឆ័យ។ របាយការណ៍នោះ និយាយថាៈ "មាត្រាមួយចំនួននៅក្នុងច្បាប់ភូមិបាលចែងពីបញ្ហានៃការកាន់កាប់ដីដោយខុសច្បាប់។ ថ្វីបើមាត្រា ៣៨ អធិប្បាយអំពីកាលៈទេសៈដែលនៅក្នុងនោះការកាន់កាប់ដីលើសពីប្រាំឆ្នាំ អាចនាំទៅដល់កម្មសិទ្ធិក្តី ក៏មាត្រា ២៩ និង ៣៤ ចែងច្បាស់ថាពុំមានការកាន់កាប់ណាដែលចាប់ផ្តើមក្រោយកាលបរិច្ឆេទនៃច្បាប់ភូមិបាល (ខែ សីហា ឆ្នាំ ២០០១) អាចនាំទៅដល់កម្មសិទ្ធិឡើយ។ មាត្រា ១៨ នៃច្បាប់ភូមិបាលកំណត់បន្ថែមទៀតនូវការកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់ និង ចាត់ទុកជាមោឃៈនូវការប៉ុនប៉ងធ្វើឱ្យស្របច្បាប់ឬធ្វើឱ្យមានភាពជាប្រក្រតីនូវការកាន់កាប់ខុសច្បាប់។ ប៉ុន្តែ នៅកម្ពុជា វាគឺជារឿងធម្មតាដែលប្រជាជនរស់នៅលើ និង ប្រកបអាជីវកម្មនៅក្នុងដីចំណីផ្លូវ។ រាជរដ្ឋាភិបាលមិនដែលបានប្រកាសថាដីចំណីផ្លូវគឺជាដីរបស់រដ្ឋទេ ហើយប្រជាជនកម្ពុជាច្រើនតែមិនដឹងអំពីចំណុចនេះ មកនៅលើតំបន់ដីចំណីផ្លូវដើម្បីដាំដំណាំ ឬ ប្រកបអាជីវកម្ម ឬ រហូតដល់ទៅសាងសង់ផ្ទះ។ រាជរដ្ឋាភិបាលមិនរារាំងការប្រើដីចំណីផ្លូវរបស់ពួកគេទេ រហូតដល់ពេលដែលរាជរដ្ឋាភិបាលត្រូវការដីនោះសម្រាប់កែលម្អផ្លូវថ្នល់ ធ្វើលូ ។ល។ ច្បាប់ភូមិបាល ហាមឃាត់ការផ្តល់សំណងជូនជនទាំងឡាយដែល "ចូលកាន់កាប់អចលនវត្ថុសាធារណៈរបស់រដ្ឋ" ឬ "ចូលកាន់កាប់

## IV. អនុសាសន៍

២៣. តាមទស្សនៈរបស់បេសកកម្មសិក្សាវាយតម្លៃ ការពាក់ព័ន្ធថែមទៀតរបស់ធនាគារពិភពលោកនៅក្នុងការរៀបចំដែនដី និងរដ្ឋបាលដីក្រោយឆ្នាំ ២០០៩ តម្រូវឱ្យគម្រោង LMAP ធ្វើសកម្មភាពកែតម្រូវផង និង សកម្មភាពសម្លឹងទៅមុខផង ដើម្បីអនុវត្តសមាសភាគសំខាន់ៗរបស់គម្រោង និង ដើម្បីពាក់ព័ន្ធជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលទាក់ទិន ឬ រងផលប៉ះពាល់ដោយរដ្ឋបាលនិងការគ្រប់គ្រងដីធ្លីបច្ចុប្បន្ននៅកម្ពុជា[២៥] ។ ដើម្បីកែតម្រូវចំណុចនេះ បេសកកម្មសិក្សាវាយតម្លៃចាត់ទុកសកម្មភាពកែតម្រូវខាងក្រោមថាមានលក្ខណៈចាំបាច់៖

ក. ធានាឱ្យបានថាមានវិធានការបណ្ដោះអាសន្នដើម្បីការពារដីរបស់ជនជាតិដើមភាគតិច រហូតដល់ពេលដែលអនុក្រឹត្យដែលត្រូវបានអនុម័តក្នុង ខែ ឧសភា ឆ្នាំ ២០០៩ ត្រូវបានអនុវត្ត ។

ខ. ជួយក្នុងការសម្រួលលទ្ធភាពទទួលបានការផ្ដល់ប័ណ្ណកម្មសិទ្ធិក្រៅប្រព័ន្ធ រួមទាំងយុទ្ធនាការព័ត៌មាន និង ការផ្ដល់ជំនួយផ្នែកច្បាប់ ជូនប្រជាពលរដ្ឋនិងសហគមន៍ ជាពិសេស ប្រជាពលរដ្ឋនិងសហគមន៍ទាំងឡាយដែលមិនត្រូវបានដាក់បញ្ចូលក្នុងកិច្ចដំណើរការផ្ដល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធនៅតំបន់ទីក្រុង ។

គ. អនុវត្តការវិនិយោគចាំបាច់ទាក់ទិននឹងការគ្រប់គ្រងដី រួមទាំងការគូសផែនទីដីរបស់រដ្ឋនៅតំបន់ទីក្រុង ដែលនៅទីនោះ ការបណ្ដេញចេញកំពុងកើតឡើងក្រោមការសន្មតថា ប្រជាជនដែលត្រូវបានបណ្ដេញចេញកំពុងប្រើប្រាស់ដីសាធារណៈរបស់រដ្ឋ ។ ប្រសិនបើដូចជាការប្រាប់ជូនបេសកកម្មសិក្សាវាយតម្លៃដែលថាចំណុចនេះគប្បីគឺជាផ្នែកមួយនៃគម្រោងបន្តការងារ/គម្រោងដោយឡែកមួយ ចំណុចនេះគប្បីត្រូវបានបំភ្លឺជាផ្លូវការជូនធនាគារពិភពលោក ហើយគោលការណ៍ត្រូវឯកភាពគ្នាអាស្រ័យលើការបំភ្លឺនេះ ។

---

អចលនវត្ថុឯកជនរបស់រដ្ឋ ក្រោយខែ សីហា ឆ្នាំ ២០០១ (កាលបរិច្ឆេទនៃច្បាប់ភូមិបាល)។" គោលនយោបាយនេះ គួបផ្សំជាមួយនឹងបទបញ្ញត្តិគោលនយោបាយនៃការទទួលស្គាល់តែសិទ្ធិនៃកម្មសិទ្ធិសម្រាប់ការផ្ដល់សំណងដី កំពុងធ្វើឱ្យមនុស្សជាច្រើនដែលប្រើដីចំណីផ្លូវ ជាពិសេសគ្រួសារនៅជនបទ ប្រឈមមុខនឹងហានិភ័យនៃការបណ្ដេញចេញនិងការធ្លាក់ចូលទៅក្នុងភាពក្រីក្រ ប្រសិនបើនិងនៅពេលដែលដីនោះត្រូវបានដកហូតសម្រាប់ការងារធ្វើផ្លូវថ្នល់។ ពួកគេអាចធ្លាក់ខ្លួនទៅជាអ្នកគ្មានផ្ទះសម្បែង និង គ្មានមធ្យោបាយផលិតកម្ម និង គ្មានមធ្យោបាយសម្រាប់រស់រានទេ។ ទន្ទឹមគ្នានឹងការទទួលស្គាល់ភាពចាំបាច់ត្រូវមានដីចំណីផ្លូវ បេសកកម្មសិក្សាវាយតម្លៃក៏ជឿផងដែរថា ប្រជាជនរងផលប៉ះពាល់នៅក្នុងដីចំណីផ្លូវចាំបាច់ត្រូវទទួលជំនួយនៅក្នុងការស្ដារជីវភាពរបស់ខ្លួនឡើងវិញ ទោះបីជាពួកគេមិនមានកម្មសិទ្ធិ និង សិទ្ធិស្របច្បាប់លើដីនោះក៏ដោយ។ គោលនយោបាយនិងការអនុវត្តបច្ចុប្បន្នរបស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវកែលម្អដើម្បីសម្រេចបានគោលបំណងនេះ។

[២៥] គម្រោង LMAP មិនត្រូវគេចវេសពីវិស័យដែលគម្រោងត្រូវបានគ្រោងជះឥទ្ធិពលលើ (រដ្ឋបាលនិងការគ្រប់គ្រងដីធ្លីនៅក្នុងខេត្ត/រាជធានី អនុវត្តគម្រោង) ដើម្បីសម្រេចបានគោលដៅរួមរបស់គម្រោងក្នុងការធានាឱ្យបាននូវសិទ្ធិដីធ្លីជូនសហគមន៍ជួបការលំបាកនិងសហគមន៍ក្រីក្រនៅតំបន់ទីក្រុង និង ជនជាតិដើមភាគតិច ។

ឃ. ពិនិត្យមើលសៀវភៅណែនាំបច្ចេកទេសសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីឡើងវិញ ដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិស្តីពីកិច្ចការពារផ្នែកបរិស្ថាននិងសង្គមកិច្ច ដែលស្របគ្នាជាមួយនឹងគោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ច និងផ្តល់ការណែនាំការអនុវត្តសមស្របជូនបុគ្គលិកគម្រោង LMAP ស្តីពីគោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ច។ កិច្ចការនេះគឺជាសកម្មភាពសំខាន់មួយ ដើម្បីធានាឱ្យបានថាគោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ចនឹងត្រូវបានប្រើតាមការកំណត់របស់វា។

ង. បញ្ចប់បង្ហើយការជ្រើសរើសអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងសកម្មភាពខាងការផ្សព្វផ្សាយសាធារណៈនិងការចូលរួមរបស់សហគមន៍រួមទាំងនៅក្នុងការពិនិត្យមើលផ្ទៃដីតំបូងដែលត្រូវវិនិច្ឆ័យ។ ការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធដីបន្ថែមគប្បីត្រូវបានកាត់បន្ថយរហូតដល់ពេលដែលចំណុចនេះត្រូវបានអនុវត្ត។

ច. ជ្រើសរើសអង្គការសហគមន៍/អង្គការមិនមែនរដ្ឋាភិបាលឯកទេសឱ្យផ្តល់ជំនួយផ្នែកច្បាប់ជូនដល់អ្នកប្រើប្រាស់ដី អ្នកជួលដី ភោគី និងជួយពួកគេក្នុងការវិភាគ និងស៊ើបអង្កេតហេតុផលស្របច្បាប់សម្រាប់ការទាមទារកម្មសិទ្ធិ/ការកាន់កាប់ ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ និង/ឬ នីតិវិធីប្តឹងតវ៉ានៅចំពោះមុខគណៈកម្មការសុរិយោដី និងតុលាការក្នុងករណីដែលការបណ្តេញចេញត្រូវបានចាត់ទុកថាចាំបាច់ ដើម្បីផលប្រយោជន៍សាធារណៈ។ រហូតដល់ពេលណាដែលមានជំនួយផ្នែកច្បាប់បែបនេះ និងដំណើរការប្រកបដោយប្រសិទ្ធភាព ធនាគារពិភពលោកត្រូវផ្តល់ឱវាទជូនរាជរដ្ឋាភិបាលឱ្យផ្អាកការបណ្តេញចេញបន្ថែមទៀត។

២៤. ម្យ៉ាងទៀត ធនាគារពិភពលោក ដោយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍គម្រោង LMAP ទាំងអស់ អាចចង់ពាក់ព័ន្ធរាជរដ្ឋាភិបាលក្នុងការពិភាក្សាគោលនយោបាយទូលាយមួយដើម្បីត្រៀមលក្ខណៈសម្រាប់ដំណាក់កាលបន្ទាប់នៃជំនួយចំពោះវិស័យដីធ្លី។ រាជរដ្ឋាភិបាល នឹងត្រូវបានផ្តល់ឱវាទសូមឱ្យ:

ក. អនុវត្តតាមគោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ចនៃគម្រោង LMAP ដើម្បីសម្រាលនិងដោះស្រាយផលប៉ះពាល់អវិជ្ជមានលើបុគ្គលនិងសហគមន៍ សម្រាប់កិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដែលត្រូវអនុវត្តនៅតាមខេត្តអនុវត្តគម្រោង រួមទាំងខេត្តថ្មីដែលត្រូវបានដាក់ចូលបន្ថែមក្នុងគម្រោង LMAP និង ដែលត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈជំនួយឥតសំណងរបស់អង្គការ CIDA។ គោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ចគប្បីត្រូវបានអនុវត្តនៅក្នុងការងារគូសផែនទី សេចក្តីសម្រេចចិត្តដោយខេត្ត/រាជធានី និង លក្ខណៈវិនិច្ឆ័យជ្រើសរើសសម្រាប់ផ្តល់ជំនួយក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ។ គោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ច ត្រូវតែត្រូវបានអនុវត្តនៅក្នុងកិច្ចដំណើរការកំណត់ព្រំដែនដីនៃតំបន់វិនិច្ឆ័យ ដោយមានការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងបុគ្គលនិងសហគមន៍រងផលប៉ះពាល់។ ចំណុចនេះគឺសំខាន់ចំពោះមុខអវត្តមាននៃគោលនយោបាយជាតិស្តីពីការតាំងលំនៅឋានថ្មី/ការផ្តល់សំណង និង ក្របខ័ណ្ឌគតិយុត្តិ។ ដោយធ្វើដូច្នេះ រាជរដ្ឋាភិបាល ក៏នឹងបំពេញផងដែរនូវអនុសាសន៍កុំឱ្យពាក់ព័ន្ធគម្រោង LMAP នៅក្នុងការកំណត់ដីជាក់ស្តែងរបស់រដ្ឋ ដោយកាត់ចេញតំបន់នានា ដែលមិនត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិ ទោះបីជាកិច្ចការនេះត្រូវបានបញ្ជាដោយខេត្ត

/រាជធានី ឬសម្រេចផ្សេងពីនេះក្តី។ ដោយឯកភាពព្រមធ្វើដូច្នេះ រាជរដ្ឋាភិបាលនឹងគាំទ្រការចុះបញ្ជីដី ការផ្តល់ប័ណ្ណកម្មសិទ្ធិដី និង គោលនយោបាយនិងនីតិវិធីវិនិច្ឆ័យ វវាងសកម្មភាពនានាដែលទទួលហិរញ្ញប្បទានពីគម្រោង LMAP និងសកម្មភាពខេត្ត/រាជធានី។

ខ. ដោយមានជំនួយពីដៃគូអភិវឌ្ឍន៍ និង ដោយមានការចូលរួមពីបុគ្គលនិងសហគមន៍រងផលប៉ះពាល់ ផ្អែកលើមូលដ្ឋានបន្ទាន់ អនុវត្តការវាយតម្លៃសង្គមលើទីកន្លែងនៃការតាំងលំនៅឋានថ្មីនៅក្នុង និង នៅជាយរាជធានីភ្នំពេញ ដែលនៅទីនោះប្រជាជនពីក្នុងក្រុងត្រូវបានផ្លាស់ទៅ នៅក្រោយពេលដែលពួកគេត្រូវបានបណ្តេញចេញនៅក្នុងអំឡុងពេលអនុវត្តគម្រោង LMAP។ ម្យ៉ាងទៀត ផែនការគប្បីត្រូវបានរៀបចំសម្រាប់ទីកន្លែងទាំងនេះដើម្បីបំពេញតាមស្តង់ដារអន្តរជាតិក្នុងការតាំងលំនៅឋានថ្មី។ គោលបំណងមួយនៃជំនួយបែបនេះ នឹងគឺជាការផ្តល់ប័ណ្ណកម្មសិទ្ធិដីនិងចុះបញ្ជីដីនៅតំបន់តាំងលំនៅឋានថ្មីទាំងនេះ ដើម្បីធានាសិទ្ធិរបស់បុគ្គលនិងសហគមន៍ដែលបានតាំងលំនៅឋានថ្មី និងដើម្បីផ្តល់ការគ្រប់គ្រងបរិស្ថានឱ្យបានល្អលើទីកន្លែងតាំងលំនៅឋានថ្មី។

គ. ក្រោយពីគម្រោង LMAP រាជរដ្ឋាភិបាលកម្ពុជា ធនាគារពិភពលោក ដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងភាគីពាក់ព័ន្ធនានា គប្បីពិភាក្សាសក្តានុពលផ្តល់ជំនួយជូនរាជរដ្ឋាភិបាលក្នុងការរៀបចំបង្ហើយគោលនយោបាយជាតិនិងអនុក្រឹត្យស្តីពីការតាំងលំនៅឋានថ្មី ដោយមានជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលត្រូវបានពិនិត្យមើលឡើងវិញដោយបេសកកម្មសិក្សាវាយតម្លៃ និង ត្រូវបានរកឃើញថាមានអនុលោមភាពដ៏ទូលាយជាមួយនឹងការអនុវត្តអន្តរជាតិល្អ រួមទាំងស្តង់ដារអង្គការ UNHCS និង គោលនយោបាយរបស់ធនាគារពិភពលោកស្តីពីការតាំងលំនៅឋានថ្មីមិនស្ម័គ្រចិត្ត។

ឃ. ក្រោយពេលវដ្តគម្រោង LMAP បច្ចុប្បន្ន បេសកកម្មសិក្សាវាយតម្លៃបានដឹងថាសាលាក្រុងនៃរាជធានីភ្នំពេញកំពុងរៀបចំផែនការប្រើប្រាស់ដី និង គោលនយោបាយលំនៅឋានមួយ។ សាលាក្រុងគប្បីប្រើឱកាសនេះដើម្បីដើម្បីធានាបន្ថែមទៀតនូវសិទ្ធិដីធ្លីជូនសហគមន៍ទាំងអស់ រួមទាំងសហគមន៍ទាំងឡាយដែលស្ថិតនៅក្នុងតំបន់ទីក្រុង និងដាក់បញ្ចូលពួកគេនៅក្នុងកិច្ចដំណើរការមួយដែលផ្តល់ប័ណ្ណកម្មសិទ្ធិដីដែលមិនស្ថិតនៅក្នុងដីសាធារណៈរបស់រដ្ឋ ដែលត្រូវបានកំណត់និងគូសព្រំដែនដីយ៉ាងច្បាស់លាស់និងប្រកបដោយតម្លាភាព។ ក្រោមអភិក្រមដ៏ច្បាស់លាស់និងប្រកបដោយតម្លាភាពបែបនេះ សហគមន៍ទាំងឡាយដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលប័ណ្ណកម្មសិទ្ធិ នឹងត្រូវបានតាំងលំនៅឋានថ្មី អនុលោមតាមគោលនយោបាយនិងអនុក្រឹត្យស្តីពីការតាំងលំនៅឋានថ្មី ដែលបានលើកឡើងខាងលើ ឬ គោលការណ៍ណែនាំផ្នែកបរិស្ថាននិងសង្គមកិច្ចគម្រោង LMAP ដែលគេបានឯកភាពគ្នា ប្រសិនបើអនុក្រឹត្យនិងគោលនយោបាយនេះនៅមិនទាន់ចូលជាធរមាន។

ង. ធនាគារពិភពលោក ត្រូវតែជួយរាជរដ្ឋាភិបាល និង សាលាក្រុងនៃរាជធានីភ្នំពេញ ក្នុងការសិក្សាពីបទពិសោធន៍របស់ប្រទេសដទៃ ដែលបានបង្ហាញរបៀបដែលការធានាសិទ្ធិដីធ្លី និងកែលម្អលំនៅឋានរខេតរខាក និងក្រុងរខេតរខាកអាចត្រូវបានប្រើជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពដើម្បីប្រយុទ្ធនឹងភាពក្រីក្រ និង លើកកម្ពស់កិច្ចដំណើរនិងលទ្ធផលការអភិវឌ្ឍន៍ ទន្ទឹមគ្នានឹងការកែលម្អបរិស្ថានទីក្រុងជារួម។

# ឧបសម្ព័ន្ធ ១

## ស្ថានភាពនៃការអនុវត្តគម្រោង LMAP គិតដល់ខែ មេសា ឆ្នាំ ២០០៩

| | សមាសភាគ | វឌ្ឍនភាព | បញ្ហានៅមិនទាន់ដោះស្រាយរួច |
|---|---|---|---|
| ១ | **ផ្នែក ក:**<br><br>អភិវឌ្ឍន៍គោលនយោបាយដីនិងក្របខ័ណ្ឌនិយ័តកម្ម | ១. ពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដី ។ | ១. អនុម័តគោលនយោបាយស្តីពីជនជាតិដើមភាគតិច និង អនុក្រឹត្តស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ( បានធ្វើក្នុងខែ ឧសភា ឆ្នាំ ២០០៩)<br>២. អនុវត្តវិធានការបណ្តោះអាសន្នដើម្បីការពារដីរបស់ជនជាតិដើមភាគតិច<br>៣. និយមន័យច្បាស់លាស់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់បានកំណត់ ។ |
| ២ | **ផ្នែក ខ:**<br><br>អភិវឌ្ឍន៍ស្ថាប័ន | ១. កសាងសមត្ថភាពដើម្បីធ្វើការផ្តល់ប័ណ្ណកម្មសិទ្ធិ នៅតាម "តំបន់គ្មានវិវាទ" ជាពិសេសនៅតំបន់ជនបទ ។<br>២. វគ្គសិក្សាស្តីពីរដ្ឋបាលដីធ្លីដែលត្រូវបានបង្រៀននៅសកលវិទ្យាល័យ | |
| ៣ | **ផ្នែក គ:**<br>កម្មវិធីនិងការអភិវឌ្ឍការផ្តល់ប័ណ្ណកម្មសិទ្ធិដី និងប្រព័ន្ធចុះបញ្ជីដីធ្លី | ១. ក្រុមចុះបញ្ជីដី (LRT) ចំនួន ៣៤ ក្រុម, ក្រុមនីមួយៗមានសមាជិកចំនួន ២៦ នាក់, ត្រូវបានបង្កើតនិងបណ្តុះបណ្តាល ។<br>២. ប័ណ្ណកម្មសិទ្ធិដីជាងមួយលានសន្លឹកត្រូវបានចេញ ភាគច្រើននៅតំបន់ជនបទ ។ | ១. ពុំមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ក្នុងការផ្សព្វផ្សាយព័ត៌មាន និង ការចូលរួមរបស់សហគមន៍ ( គេច្រើនហៅថាការយល់ដឹងសាធារណៈនិងការចូលរួមរបស់សហគមន៍ - PACT) នៅក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ ។ |

| | | | |
|---|---|---|---|
| | | ៣. វឌ្ឍនភាពលើការគ្រប់គ្រងនិងការយកទិន្នន័យមកប្រើទាក់ទិននឹងប័ណ្ណកម្មសិទ្ធិដែលបានចេញ។ | ២. មូលហេតុមិនច្បាស់លាស់នៃការកាត់តំបន់ចេញពីការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ ដែលជាហេតុដកចេញប្រជាជនមួយចំនួនពីការផ្តល់ប័ណ្ណកម្មសិទ្ធិ។<br>៣. ពុំមានការផ្តល់ប័ណ្ណកម្មសិទ្ធិក្រៅប្រព័ន្ធត្រូវបានធ្វើក្រោមគម្រោងទេ។<br>៤. ការសម្រេចជាយុទ្ធសាស្ត្រនៃគម្រោង[២៦] ក្នុងការការផ្តល់ប័ណ្ណកម្មសិទ្ធិជូនតែដីមិនមានវិវាទ និង ទុកឱ្យដីនៅសល់មិនបានទទួលប័ណ្ណកម្មសិទ្ធិ គប្បីត្រូវបានពិចារណាឡើងវិញ។ |
| ៤ | **ផ្នែក ឃ:**<br>ពង្រឹងយន្តការដោះស្រាយវិវាទ | ១. គាំទ្រប្រព័ន្ធគណៈកម្មាការសុរិយោដី (Cadastral Commission)។ | ១. ពុំមានអង្គការមិនមែនរដ្ឋាភិបាល/អង្គការសហគមន៍ឯកទេស ត្រូវបានជួលឱ្យផ្តល់ជំនួយជូនសហគមន៍ជួបការលំបាកដែលពាក់ព័ន្ធក្នុងវិវាទដីធ្លី។<br>២. ប្រព័ន្ធរបស់គណៈកម្មការសុរិយោដី អាចមានហានិភ័យចំពោះមុខការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ហើយការបែងចែកការទទួលខុសត្រូវ មានលក្ខណៈមិនច្បាស់លាស់។ |
| ៥ | **ផ្នែក ង:**<br>ការរៀបចំដែនដី | | មិនត្រូវបានអនុវត្តទេ ក្រៅពីសកម្មភាពតូចតាច។ |

[២៦] ពោលគឺ មិនត្រូវបានចែងឱ្យបានច្បាស់លាស់នៅក្នុងឯកសារវាយតម្លៃគម្រោង និង មិនសុទ្ធតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ទេ។ សូមមើលឧបសម្ព័ន្ធ ២ ខាងក្រោម។

# ឧបសម្ព័ន្ធ ២

## សេចក្តីដកស្រង់ពីឯកសារវាយតម្លៃគម្រោង និង ឯកសារផ្សេងទៀតនៃគម្រោង LMAP ស្តីពីបញ្ហានៃការផ្តល់ឬមិនផ្តល់ប័ណ្ណកម្មសិទ្ធិជូនដីមានវិវាទ

### ឯកសារព័ត៌មានគម្រោង (PID) (ទំព័រ ១២)

ផ្នែកស្តីពីកិច្ចការពារៈ ការតាំងលំនៅឋានថ្មីៈ

"កិច្ចព្រមព្រៀងត្រូវបានឈានដល់ ជាមួយក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់ ទាក់ទិននឹងអភិក្រមដែលត្រូវប្រើនៅក្នុងករណីនៃអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ រួមទាំងអ្នកតាំងលំនៅឋានអនាធិបតេយ្យ ។ គម្រោងៈ

(ក) នឹងចេញប័ណ្ណកម្មសិទ្ធិដីនៅទីណាដែលមានការយល់ព្រមពីរាជរដ្ឋាភិបាលក្នុងការផ្តល់ដីដែលត្រូវចុះបញ្ជីជូនដល់អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ ។

(ខ) នឹងជួយសម្រួលការផ្តល់សេវា និងការផ្តល់ប័ណ្ណកម្មសិទ្ធិនៅទីណាដែលសាលាក្រុងកំពុងធ្វើការជាមួយក្រុមអភិវឌ្ឍន៍នានាដើម្បីផ្តល់ដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋានផ្អែកលើគោលការណ៍នៃមជ្ឈមណ្ឌលសហប្រជាជាតិសម្រាប់ការតាំងលំនៅឋានមនុស្ស (UNCHS) និង

(គ) នឹងមិនចេញប័ណ្ណកម្មសិទ្ធិទេ នៅទីណាដែលពុំមានកិច្ចព្រមព្រៀងក្នុងការបែងចែកដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ ឬ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋាន ។

កម្មវិធីរបស់អង្គការ UNCHS គឺផ្អែកលើគោលការណ៍អន្តរជាតិសម្រាប់ជម្រក ពោលគឺ

(ក) ផ្តល់សុវត្ថិភាពនៃការកាន់កាប់ ។

(ខ) ជម្រុញសិទ្ធិមានលំនៅឋានគ្រប់គ្រាន់ ។

(គ) ផ្តល់លទ្ធភាពទទួលដីស្មើគ្នា ។

(ឃ) ជម្រុញលទ្ធភាពទទួលឥណទានស្មើគ្នា និង

(ង) ជម្រុញលទ្ធភាពទទួលសេវានិងគោលការណ៍ណែនាំជាមូលដ្ឋាន ។

គម្រោងបានរៀបចំនីតិវិធីសម្រាប់ពិនិត្យចម្រាញ់ និង សម្រាប់ការពិគ្រោះយោបល់ ដើម្បីធានាឱ្យបានថាល័ក្ខខ័ណ្ឌខាងលើនេះត្រូវបានឯកភាពគ្នាមុនពេលផ្តល់សេវាចុះបញ្ជីនិងផ្តល់ប័ណ្ណកម្មសិទ្ធិដី ។ ដោយសារគម្រោងនឹងផ្តល់ហិរញ្ញប្បទានដល់ការសាង

សង់អគារការិយាល័យថ្មីមួយជូនក្រសួង និង ការស្ថានីតិសម្បទា/ការសាងសង់ថ្មីនូវការិយាល័យសុរិយោដីខេត្តនិងស្រុក មានការឯកភាពជាមួយរាជរដ្ឋាភិបាលការិយាល័យទាំងនេះនឹងត្រូវបានសាងសង់លើដីទំនេរ។"

## ឯកសារវាយតម្លៃគម្រោង (ទំព័រ ១២)

៣. ...."គម្រោងនេះប្រកាន់យកវិធានការដ៏ពេញលេញមួយក្នុងការគាំទ្រកំណែទម្រង់គោលនយោបាយនិងនិយ័តកម្ម ការកសាងការស្រុះស្រួលគ្នា និង ការអភិវឌ្ឍស្ថាប័ន រួមជាមួយការផ្តល់ប័ណ្ណកម្មសិទ្ធិដី។ គម្រោងនេះកំណត់យ៉ាងប្រុងប្រយ័ត្ននូវលំដាប់លំដោយសកម្មភាព ដើម្បីកុំឱ្យការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធកើតឡើងនៅលើដីដែលមានស្ថានភាពមិនច្បាស់លាស់រហូតដល់ពេលដែលស្ថានភាពនេះត្រូវបានព្រមព្រៀងជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស ហើយព្រំដែនរវាងដីឯកជននិងដីរបស់រដ្ឋត្រូវបានគូសកំណត់ព្រំប្រទល់។"

..."នៅក្នុងអំឡុងពេលនៃការធ្វើចំណាត់ថ្នាក់ដី និង ការគូសព្រំដែនដី ភាគីពាក់ព័ន្ធទាំងអស់នឹងចូលរួមក្នុងកិច្ចដំណើរការមួយនៃការពិគ្រោះយោបល់សាធារណៈដើម្បីធានាឱ្យបាននូវការព្រមព្រៀងគ្នាទូទៅជាមួយសេចក្តីសម្រេចចិត្តនានា។ នៅក្នុងអំឡុងពេលធ្វើការវិនិច្ឆ័យជាប្រព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលដែលមានការបណ្តុះបណ្តាលឯកទេសលើការចូលរួម នឹងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកភូមិ ដោយពន្យល់អំពីនីតិវិធីផលិតឯកសារដីរបស់ភូមិ និង ធានាឱ្យបានថាសមាជិកទាំងអស់នៃសហគមន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលប័ណ្ណកម្មសិទ្ធិដី នឹងទទួលបានអត្ថប្រយោជន៍ ពីគម្រោង។"

## ឯកសារវាយតម្លៃគម្រោង (ទំព័រ ១៨)

៥.១... "គម្រោងក៏នឹងគាំទ្រផងដែរដល់ការអភិវឌ្ឍនីតិវិធី និងការអនុវត្តការរៀបចំផែនទីចំណាត់ថ្នាក់ដីនៅតាម ***ខេត្តអនុវត្តគម្រោង*** ដែលកំណត់ព្រំដែនដីរវាងប្រភេទផ្សេងៗនៃការប្រើប្រាស់ដី ដូចជា ទីក្រុង ព្រៃឈើកសិកម្ម និង តំបន់ការពារ ជាដើម។ ការរៀបចំផែនទីទាំងនេះ នឹងត្រូវបានធ្វើតាមរយៈកិច្ចដំណើរការដោយមានការចូលរួមមួយនៅក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិផ្សេងៗ ដើម្បីធានាឱ្យបាននូវកិច្ចការពារបរិស្ថាននិងជម្រកធម្មជាតិ។"

## ឯកសារវាយតម្លៃគម្រោង (ទំព័រ ១៩)

៦.១. "**វិធានការនានាដើម្បីជួយសហគមន៍ជួបការលំបាកៈ** នៅក្នុងអំឡុងពេលអនុវត្តគម្រោង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនឹងត្រូវបានជួលឱ្យជួយសម្រួលការចូលរួមរបស់សហគមន៍នៅក្នុងអំឡុងពេលការវិនិច្ឆ័យជាប្រព័ន្ធ។ អង្គការទាំងនេះនឹងទទួលបន្ទុកលើការងារក្នុងមូលដ្ឋាន មុនពេលចាប់ផ្តើមការការវិនិច្ឆ័យជាប្រព័ន្ធ។ វិសាលភាពការងាររបស់ពួកគេនឹងរួមមានភារកិច្ចខាងក្រោមនេះៈ ផ្សព្វផ្សាយព័ត៌មាន ដោយផ្តោតលើស្ត្រីសម្រាប់យុទ្ធនាការអប់រំអំពីច្បាប់ភូមិបាល

និងនីតិវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ ធ្វើការកំណត់ស្ថានភាពចំណុចផ្តើមរបស់ភូមិ បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធទិន្នន័យអំពីការចុះបញ្ជី វិភាគឯកសារចុះបញ្ជី ផលិតឯកសារដីភូមិសរុប ពន្យល់អំពីអត្ថប្រយោជន៍និងនីតិវិធីសម្រាប់ចុះបញ្ជីការផ្ទេរ នៅពេលក្រោយ និង ផ្តល់ការជួយគាំទ្រដល់ការធ្វើផែនការប្រើប្រាស់ដីក្នុងមូលដ្ឋាន និង ការវាយតម្លៃនិងការតាមដាន។ គម្រោងនឹងផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាលដែលបានជួលនូវការពន្យល់បង្ហាញនិងការបណ្តុះបណ្តាល រួមទាំងការបណ្តុះបណ្តាលលើវិធីសាស្ត្រយេនឌ័រជាក់លាក់ និង ឧបករណ៍សម្រាប់ការចូលរួម។"

## ឯកសារវាយតម្លៃគម្រោង (ទំព័រ ២០)

៦.១. **"អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ**។ កិច្ចព្រមព្រៀងត្រូវបានឈានដល់ជាមួយក្រសួង (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់) ទាក់ទិននឹងអភិក្រមដែលត្រូវប្រើក្នុងករណីនៃអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ រួមទាំងអ្នកតាំងលំនៅឋានអនាធិបតេយ្យ។ គម្រោងៈ

(ក) ***នឹងចេញប័ណ្ណកម្មសិទ្ធិដី*** នៅទីណាដែលមានការយល់ព្រម ពីរាជរដ្ឋាភិបាលក្នុងការផ្តល់ដីដែលត្រូវចុះបញ្ជីជូនដល់អ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ

(ខ) នឹងជួយសម្រួលការផ្តល់សេវា និងការផ្តល់ប័ណ្ណកម្មសិទ្ធិនៅទីណាដែលសាលាក្រុងកំពុងធ្វើការជាមួយក្រុមអភិវឌ្ឍន៍នានាដើម្បីផ្តល់ដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋានផ្អែកលើគោលការណ៍នៃមជ្ឈមណ្ឌលសហប្រជាជាតិសម្រាប់ការតាំងលំនៅឋានមនុស្ស (UNCHS) និង

(គ) ***នឹងមិនចេញប័ណ្ណកម្មសិទ្ធិទេ*** នៅទីណាដែលពុំមានកិច្ចព្រមព្រៀងក្នុងការបែងចែកដីជូនអ្នកតាំងលំនៅឋានក្រៅប្រព័ន្ធ ឬ តាមរយៈការចែករំលែកដី និង/ឬ កម្មវិធីផ្លាស់លំនៅឋាន។ ***គម្រោងបានរៀបចំនីតិវិធីសម្រាប់ពិនិត្យចម្រាញ់ និង សម្រាប់ការពិគ្រោះយោបល់ ដើម្បីធានាឱ្យបានថាល័ក្ខខ័ណ្ឌខាងលើនេះត្រូវបានឯកភាពគ្នាមុនពេលផ្តល់សេវាចុះបញ្ជីនិងផ្តល់ប័ណ្ណកម្មសិទ្ធិដី។"***

## ឯកសារវាយតម្លៃគម្រោង (ទំព័រ ២៤)

៣. ***ទិដ្ឋភាពដែលអាចមានលក្ខណៈចម្រូងចម្រាស់***: "ការធ្វើចំណាត់ថ្នាក់ដីនិងការគូសកំណត់ព្រំដែលរវាងដីសាធារណៈ និងដីឯកជន និង សម្រាប់ដីនៅក្នុងវិស័យសាធារណៈ ដីក្រោមការគ្រប់គ្រងរបស់ស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗ ច្រើនតែមានលក្ខណៈពិបាក និង អាចបង្កើនវិវាទនៅក្នុងរយៈពេលខ្លី។ ***គម្រោងនឹងមិនផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅតាមតំបន់ទាំងឡាយដែលនៅទីនោះទំនងជាមានវិវាទ រហូតដល់ពេលមានកិច្ចព្រមព្រៀងគ្នាអំពីស្ថានភាពដី។ គម្រោងនឹងគាំទ្រកិច្ចដំណើរការពិគ្រោះយោបល់សាធារណៈ ដើម្បីជួយស្តាបនាការស្រុះស្រួលគ្នាសម្រាប់សេចក្តីសម្រេចចិត្តនានា និង នឹងធានាឱ្យបាននូវ***

***ការពិភាក្សានិងការពិគ្រោះយោបល់ជាបន្តជាមួយអង្គការមិនមែនរដ្ឋាភិបាល និង សង្គមស៊ីវិល។ គេបានរំពឹងថាដីមួយចំនួនដែលនៅពេលនេះជាទាមស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ (ប្រហែល ៨០% នៃផ្ទៃដីសរុប) នឹងត្រូវបានប្រគល់ជូនផ្តែកឯកជន។ ប្រការនេះនឹងធ្វើរាជរដ្ឋាភិបាលមានធនធាន ដើម្បីគ្រប់គ្រងឱ្យបានកាន់តែប្រសើរឡើងនូវផ្ទៃដីទាំងឡាយដែលស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន។"***

**ឯកសារវាយតម្លៃគម្រោង (ទំព័រ ៣៥)**

**សេចក្តីអធិប្បាយអំពីគម្រោង**

សមាសភាគទី ៣ នៃគម្រោង - ***កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដី និង អភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីដី***

(២០,៤០ លានដុល្លារអាមេរិក)

"សមាសភាគនេះ នឹងគាំទ្រការចេញប័ណ្ណកម្មសិទ្ធិដីលើកដំបូងបង្អស់ និង ការបង្កើតប្រព័ន្ធចុះបញ្ជីដីធ្លីដើម្បីចុះបញ្ជីការលក់ដូរដី និង នឹងរួមមាន: (ក) ការផ្សព្វផ្សាយព័ត៌មាន និង ការចូលរួមរបស់សហគមន៍ (ខ) កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ (គ) កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីក្រៅប្រព័ន្ធ និង (ឃ) អភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីដីធ្លីមួយដែលមានភាពស័ក្តិសិទ្ធ តម្លាភាព និង ប្រសិទ្ធិភាព។

**ក.** ***ការផ្សព្វផ្សាយព័ត៌មាន និង ការចូលរួមរបស់សហគមន៍:***

សមាសភាគរងនេះ នឹងគាំទ្រការផ្សព្វផ្សាយព័ត៌មានតាមរយៈបណ្តាញសារព័ត៌មាន (ទូរទស្សន៍ វិទ្យុ និង កាសែត) និង ប័ណ្ណប្រកាសអំពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធនិងក្រៅប្រព័ន្ធ និង ការចុះបញ្ជីការលក់ដូរដី។ ការផ្សព្វផ្សាយព័ត៌មាន ក៏ដាក់បញ្ចូលផងដែរនូវការផ្សព្វផ្សាយព័ត៌មានគាំទ្រជូនដល់អ្នកភូមិដែលឆ្លងកាត់ការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ។ មុនពេលចាប់ផ្តើមសកម្មភាពផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅក្នុងភូមិ គម្រោងនឹងរៀបចំយុទ្ធនាការព័ត៌មានមួយ តាមរយៈការពិភាក្សាក្រុមគោលដៅ និង សិក្ខាសាលាដើម្បីពន្យល់អំពីគោលដៅគម្រោង ហេតុផល និង អត្ថប្រយោជន៍ និង នឹងពន្យល់ផងដែរអំពីទម្រង់ នីតិវិធី និង សិទ្ធិស្របច្បាប់ជូនដល់គ្រួសារនីមួយៗ។ យុទ្ធនាការព័ត៌មាននេះ នឹងចាប់ផ្តើមប្រហែលជាមួយខែមុនពេលដែលការចុះពិនិត្យនិងការផ្តល់ប័ណ្ណកម្មសិទ្ធិ ចាប់ផ្តើម។

***គម្រោងនឹងជួលនិងបណ្តុះបណ្តាលអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកក្នុងខេត្តអនុវត្តគម្រោង*** ដើម្បីអនុវត្តការផ្សព្វផ្សាយព័ត៌មាននិងយុទ្ធនាការចងក្រងសហគមន៍នៅថ្នាក់ភូមិ រួមមានការបណ្តុះបណ្តាលនិងការចូលរួមរបស់អង្គការមហាជននានា ដូចជាសមាគមកសិករជាដើម។ ***សមាសភាគរងនេះ ក៏នឹងដាក់បញ្ចូលផងដែរនូវការជួយគាំទ្រដល់ការប្រមូលព័ត៌មានដីភូមិដើម្បីកំណត់ព្រំដែនភូមិ អធិប្បាយអំពីការបែងចែកដី សកម្មភាព***

***ទីផ្សារដី និង កំណត់វិវាទដីធ្លីដែលមានតាំងពីពេលមុន***។ព័ត៌មាននេះនឹងត្រូវបានប្រើនៅក្នុងការធ្វើផែនការនៃកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិ និង នៅពេលបន្ទាប់ សម្រាប់តាមដានផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ចរបស់គម្រោង។ ស្តង់ដារទម្រង់មួយសម្រាប់ប្រមូលទិន្នន័យនឹងត្រូវបានរៀបចំនៅក្នុងអំឡុងពេលមុនការអនុវត្តគម្រោង។ ទិន្នន័យទាំងនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងទិន្នន័យកុំព្យូទ័រដើម្បីងាយរកនិងងាយប្រើ។

## ខ. ***កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ***

សមាសភាគរងនេះ នឹងគាំទ្រគំនិតផ្តួចផ្តើមបច្ចុប្បន្នរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដី (ការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីដំបូងបំផុត) រួមជាមួយនឹងការអភិវឌ្ឍបន្ថែមទៀត និងការបង្កើនល្បឿនគម្រោងសាកល្បងកំពុងដំណើរការចំនួនពីរដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលហ្វាំងឡង់និងអាល្លឺម៉ង់។ ***កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីនឹងគ្របដណ្តប់លើខេត្តចំនួន ១០ និង រាជធានីភ្នំពេញ***(ឯកសារភ្ជាប់ ១១) និង ***នឹងគ្របដណ្តប់ទាំងតំបន់ទីក្រុងនិងតំបន់ជនបទ***។

សមាសភាគរងនេះ នឹងរួមមានសកម្មភាពដូចតទៅនេះ: [......] "ការបណ្តុះបណ្តាលដើម្បីគាំទ្រដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីឱ្យបានលឿន" (១) .......... (២) ***សម្រាប់ក្រុមចុះបញ្ជីជាប្រព័ន្ធនៅក្នុងកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ ច្បាប់ភូមិបាល ការជួយសម្រួលការចូលរួម និង ការសម្រុះសម្រួលវិវាទ*** និង (៣) ការបណ្តុះបណ្តាលបុគ្គលិកខេត្តនិងស្រុកលើប្រធានបទច្បាប់ បច្ចេកទេស និង គ្រប់គ្រង [......]

## គ. ***កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីក្រៅប្រព័ន្ធ:***

សមាសភាគនេះ នឹងគាំទ្រការចេញប័ណ្ណកម្មសិទ្ធិ (ការចេញនិងការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីលើកដំបូងបំផុត) តាមតម្រូវការនៅក្នុងខេត្តអនុវត្តគម្រោង។ ការជួយគាំទ្រនេះ នឹងរួមមាន:

១. ពិនិត្យឡើងវិញនូវនីតិវិធីបច្ចុប្បន្នសម្រាប់ការចេញប័ណ្ណកម្មសិទ្ធិដី និង ផ្តល់ការកែសម្រួលប្រសិនបើចាំបាច់

២. រៀបចំសៀវភៅណែនាំស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិជាប្រព័ន្ធ

៣. ការបណ្តុះបណ្តាលបុគ្គលិកការិយាល័យខេត្តនិងស្រុកអំពីនីតិវិធីថ្មី និង

(i) [.......]